## អារម្ភកថា

សៀវភៅសង្ខេបទ្រឹស្ដីអក្សរសិល្ប៍ខ្មែរនេះ គឺជាស្នាដៃមួយដែលងាយស្រួលដល់អ្នកសិក្សា ក្នុងការឈ្វេងយល់និងសិក្សាស្រាវជ្រាវក្នុងវិស័យអក្សរសិល្ប៍ ព្រោះវាមានខ្លឹមសារសង្ខេបខ្លីៗដែលល្អសម្រាប់អ្នកសិក្សា ដើម្បីទាញយកពុទ្ធិនិងធ្វើឱ្យអ្នកសិក្សាងាយចាំ ងាយចេះនូវទ្រឹស្ដីអក្សរសិល្ប៍ខ្មែរបានយ៉ាងឆាប់រហ័សទៀតផង។

ទោះបីជាសៀវភៅនេះ វាមិនល្អឥតខ្ចោះក្តី តែយ៉ាងណាវាក៏ជាឯកសារជំនួយស្មារតីសំខាន់មួយសម្រាប់មិត្តអ្នកសិក្សា អ្នកស្រាវជ្រាវ អ្នកអាន ដើម្បីទាញយកប្រយោជន៍ ពុទ្ធិសម្រាប់ខ្លួនឯងផងដែរ។

ខ្ញុំសូមអភ័យទោសចំពោះកំហុសខ្វះខាតផ្នែកអត្ថន័យ និងអក្ខរាវិរុទ្ធដែលមាននៅក្នុងសៀវភៅនេះ ហើយខ្ញុំសូមទទួលការរិះគន់ ដើម្បីស្ថាបនាពីអ្នកសិក្សាទាំងអស់គ្នា។

ជាចុងក្រោយខ្ញុំសូមជូនពរដល់មិត្តអ្នកសិក្សាគ្រប់រូប សូមទទួលបានជោគជ័យក្នុងការសិក្សារៀនសូត្រទាំងអស់គ្នា។

ថ្ងៃពុធ ២រោច ខែមាឃ សប្តស័ក ព.ស.២៥៦៩

វិ.ថ្មពួក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៦

**នី ឆាវ៉ា**

# មាតិកា


| ខ្លឹមសារ | ទំព័រ |
|---|---|
| ១. និយមន័យ | ១ |
| ២. ប្រភេទអក្សរសិល្ប៍ | ២ |
| ៣. ចលនាអក្សរសិល្ប៍ | ១២ |
| ៤. លក្ខណៈអក្សរសិល្ប៍ | ២៤ |
| ៥. ប្រភពអក្សរសិល្ប៍ | ២៩ |
| ៦. ភារកិច្ចអក្សរសិល្ប៍ | ២៩ |
| ៧. វត្ថុបំណងអក្សរសិល្ប៍ | ៣០ |
| ៨. មុខងារអក្សរសិល្ប៍ | ៣១ |
| ៩. តួអង្គក្នុងអក្សរសិល្ប៍ | ៣២ |
| ១០. វិធីតែងនិពន្ធ | ៣៥ |
| ១១. ការសិក្សាអត្ថបទ(គម្រោងសិក្សាអក្សរសិល្ប៍) | ៣៧ |
| ១២. កាព្យរូបារម្មណ៍ | ៤០ |
| ១៣. ការវិវត្តនៃអក្សរសិល្ប៍ | ៤២ |
| ១៤. ស្នេហាក្នុងអក្សរសិល្ប៍ | ៥០ |
| ១៥. ឯកសារយោង | ៥២ |

# ទ្រឹស្តីអក្សរសិល្ប៍

**ទ្រឹស្តីអក្សរសិល្ប៍** ជាវិទ្យាសាស្ត្រសិក្សាពីក្រឹតក្រមឆ្លុះបញ្ចាំងតថភាពនៃអក្សរសិល្ប៍។ ទ្រឹស្តីអក្សរសិល្ប៍សិក្សាពីសារជាតិសង្គម និងលក្ខណៈពិសេសនៃអក្សរសិល្ប៍។ ទ្រឹស្តីអក្សរសិល្ប៍សិក្សាស្រាវបញ្ហាទាំងឡាយដែលអក្សរសិល្ប៍បានជះឥទ្ធិពលទៅលើជីវភាពសង្គមទៅលើដំណើរនិម្មិតកម្មរបស់អ្នកនិពន្ធជាដើម។ ក្រៅពីនេះទ្រឹស្តីអក្សរសិល្ប៍មានភារកិច្ចប្រមូលផ្តុំការសិក្សាស្រាវជ្រាវរកឱ្យឃើញនូវក្រឹតក្រមទាំងឡាយដែលទាក់ទងនឹងវិធីនិម្មិតកម្មអក្សរសិល្ប៍ លក្ខណៈវិនិច្ឆ័យ សិល្បៈនៃអក្សរសិល្ប៍ ដំណើរការអភិវឌ្ឍនៃអក្សរសិល្ប៍នៅគ្រប់សម័យកាល គ្រប់ទំនោរអក្សរសិល្ប៍។

## និយមន័យអក្សរសិល្ប៍

- **អក្សរសិល្ប៍** ជាកម្រងអត្ថបទស្នាដៃដែលអ្នកនិពន្ធតាក់តែងឡើងប្រកបដោយសិល្បវិធីខ្ពស់។
- **អក្សរសិល្ប៍** ជាវិទ្យាសាស្ត្រដែលបានលើកយកពីបញ្ហាមនុស្សមកចោទនឹងដោះស្រាយទៅតាមការពិតនៃសម័យកាលដែលគេរស់នៅដោយប្រើសិល្បវិធី។
- **អក្សរសិល្ប៍** គឺជាវិទ្យាស្បង់ ដែលចោទនិងដោះស្រាយពីបញ្ហាមនុស្សដោយសិល្បវិធីនិងទៅតាមសង្គមនីមួយៗ។**(កេង វ៉ាន់សាក់)**
- **អក្សរសិល្ប៍** គឺជាសិល្បៈនៃការសម្តែងតាមអក្សរ ឬការប្រើអក្សរដើម្បីបញ្ចេញទស្សនៈឬចក្ខុសម្ផស្ស។ **(ជ័យ ចាប)**
- **អក្សរសិល្ប៍** គឺជាមែកធាងមួយនៃសិល្បៈ ព្រោះសិល្បៈគេយកតួអក្សរមកធ្វើជាសិល្បៈរចនាបានជាប្រភេទស្នាដៃផ្សេងៗគ្នា ដូចជា សិល្បៈប្រើអក្សរជាពាក្យរាយ ពាក្យកាព្យ សម្រាប់សម្តែងរឿងល្ខោនសម្រាប់សម្តែងវោហារ...។ **(លោក អេថៃប ឡាប្លេនី )**
- **អក្សរសិល្ប៍** គឺជាការសិក្សាពីមនុស្ស។ **(ម៉ាកស៊ីម គ័រគី ជនជាតិរុស្ស៊ី)**
- **អក្សរសិល្ប៍** គឺជាអាវុធសម្រាប់តស៊ូសង្គម និងជាកម្រងឯកសារនៃជីវិត។**(ប៊ីយេលិនស្គី ឆេនីសូវស្គី ដូប្រូលីយូបូវ ជនជាតិរុស្ស៊ី )**
- **អក្សរសិល្ប៍** គឺជាវិទ្យាសាស្ត្រសិក្សាពីហេតុការណ៍ ក្រឹត្យក្រម និងការអភិវឌ្ឍសង្គម។

# ប្រភេទអក្សរសិល្ប៍

អក្សរសិល្ប៍ខ្មែរត្រូវបានគេបែងចែកជាបីប្រភេទ គឺអក្សរសិល្ប៍បុរាណ អក្សរសិល្ប៍ប្រជាប្រិយ អក្សរសិល្ប៍ទំនើប។

## ១. អក្សរសិល្ប៍បុរាណ

### ក. និយមន័យ

**អក្សរសិល្ប៍បុរាណ** គឺជាអក្សរសិល្ប៍ដែលកើតឡើងតាំងពីសម័យបុរាណ ហើយអ្នកនិពន្ធនិយាយរៀបរាប់ពីរឿងរ៉ាវ ពាក់ព័ន្ធនឹងជំនឿសាសនា និងរឿងរ៉ាវប្លែកៗពិតខ្លះ បំផ្លើសខ្លះ។ អត្ថបទស្នាដៃអក្សរសិល្ប៍បុរាណភាគច្រើនមានឈ្មោះអ្នកនិពន្ធ និងមានកាលបរិច្ឆេទច្បាស់លាស់ ហើយអត្ថបទ ភាគច្រើនសរសេរជាកំណាព្យ។

### ១.១. ប្រភពអក្សរសិល្ប៍បុរាណ

អក្សរសិល្ប៍បុរាណ គឺជាស្នាដៃដែលបានទទួលឥទ្ធិពលពី
សាសនាជួនកាលការសរសេរឡើងក្នុងគោលបំណងជួយផ្សព្វផ្សាយឱ្យសាសនាផងដែរ។ គេឃើញថាមានទទួលឥទ្ធិពល ពីសាសនាធំៗពីរគឺព្រហ្មញ្ញសាសនា ដូចជារឿងរាមកេរ្តិ៍ រឿងមហាភារតយុទ្ធ រឿងកូរសមុទ្រទឹកដោះ...និងព្រះពុទ្ធ សាសនា ដូចជារឿងវេស្សន្តរ រឿងតេមិយ រឿងក្រុងសុភមិត្រ...។

### ១.២. គោលបំណងនៃអក្សរសិល្ប៍បុរាណ

- គោលបំណងនៃអក្សរសិល្ប៍បុរាណគឺ
  - អប់រំមនុស្សឱ្យជឿលើអាទិទេព វត្ថុស័ក្តិសិទ្ធិ
  - អប់រំមនុស្សឱ្យជឿលើកម្លាំងក្រៅខ្លួន
  - អប់រំមនុស្សឱ្យរស់នៅស្ងប់ស្ងៀមក្រោមអំណាចមួយដោយជឿលើកម្មផល។

### ១.៣. បញ្ហាទំនាស់និងដំណោះស្រាយ

-**ទំនាស់** គឺរវាងអាទិទេព ឬអវតារ ជាមួយសភាវអាក្រក់ និងទំនាស់រវាងតួអង្គព្រះពោធិសត្វជាមួយខ្លួនឯង ឬមារ។

-**ដំណោះស្រាយ** គឺការប្រើសង្គ្រាម ចំពោះរឿងបែបព្រហ្មនិយមនិងប្រើសន្តិវិធី ខន្តីវិធី អហិង្សាវិធីចំពោះរឿងបែបពុទ្ធនិយម។

## ខ. ប្រភេទអក្សរសិល្ប៍

- **អក្សរសិល្ប៍បុរាណចែកចេញជាបីប្រភេទគឺ**

- សិលាចារឹក
- ស្លឹករឹត-ក្រាំង
- សាស្រ្តា (សាស្រ្តាទេសន៍ សាស្រ្តាល្បែង សាស្រ្តាក្បួន)

## ២. អក្សរសិល្ប៍ប្រជាប្រិយ

### ក. និយមន័យ

**អក្សរសិល្ប៍ប្រជាប្រិយ** គឺជាអក្សរសិល្ប៍ដែលកើតឡើងពីការនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយ ពីសម័យកាលមួយទៅសម័យកាលមួយ ពីតំបន់មួយទៅតំបន់មួយ ហើយគ្មានឈ្មោះអ្នកនិពន្ធ និង កាលបរិច្ឆេទច្បាស់លាស់។

### ខ. ប្រភពអក្សរសិល្ប៍ប្រជាប្រិយ

អក្សរសិល្ប៍ប្រជាប្រិយមានប្រភពមកពីប្រជារាស្រ្តខ្មែរ ស្រុកស្រែចម្ការ តាមជនបទដែលទាក់ទងនឹង ជីវភាពរស់នៅជាក់ស្តែង។ គេអាចនិយាយថាអក្សរសិល្ប៍ប្រជាប្រិយ គឺជាអក្សរសិល្ប៍របស់មហាជន ដែលកើតឡើងក្នុងរយៈកាលធ្វើពលកម្ម និងការតស៊ូប្រឆាំងរាល់ការលំបាកក្នុងជីវភាពដើម្បីជីវិតរស់នៅ តាំងពីសង្គមគ្មានវណ្ណៈរហូតទៅដល់សង្គមមានវណ្ណៈ។

### គ. មុខងារឬតួនាទីអក្សរសិល្ប៍ប្រជាប្រិយ

អក្សរសិល្ប៍ប្រជាប្រិយមានមុខងារបម្រើផលប្រយោជន៍មហាជន ពលករ កសិករគ្រប់ស្រទាប់វណ្ណៈ។

### ឃ. ឧត្តមគតិរឿង ឬគោលបំណង

អក្សរសិល្ប៍ប្រជាប្រិយមានគោលបំណងអប់រំឱ្យអ្នកអាន អ្នកស្តាប់ដូចជា៖

-អប់រំឱ្យមានគំនិតស្នេហាជាតិ
-អប់រំឱ្យមានចិត្តក្លាហាន មិនតក់ស្លុត ការរើបម្រាស់នឹងការជិះជាន់ និងអយុត្តិធម៌
-អប់រំមនុស្សឱ្យមានក្តីសង្ឃឹមក្នុងជីវិតជានិច្ច
-អប់រំមនុស្សឱ្យមានការតស៊ូ យកបញ្ញា ប្រាជ្ញាដោះស្រាយបញ្ហា និងមានសាមគ្គីភាព
-អប់រំមនុស្សឱ្យប្រឆាំងនឹងជំនឿអរូបិយនិយម
-អប់រំមនុស្សឱ្យស្វែងរកសេចក្តីសុខតាមបែបលក្ខណៈជឿនលឿន។

### ង. បញ្ហាទំនាស់

បញ្ហាទំនាស់គឺជាទំនាស់ដែលកើតឡើងរវាងវណ្ណៈខ្លាំងនិងវណ្ណៈខ្សោយ ជាទំនាស់រវាងមនុស្សនិង មនុស្ស និងជាទំនាស់ដែលបានជួបប្រទះនៅក្នុងសង្គមក្នុងជីវភាពប្រចាំថ្ងៃ។

### ច. ដំណោះស្រាយបញ្ហាឬទំនាស់

ដំណោះស្រាយក្នុងរឿងបែបប្រជាប្រិយគឺ ការប្រើសន្តិវិធី ប្រើប្រាជ្ញាជាមូលដ្ឋាន ការប្រើកម្លាំងសាមគ្គី និងឱ្យតម្លៃលើអំពើយុត្តិធម៌ ដោយតួអង្គទន់ខ្សោយត្រូវបានគេជិះជាន់នឹងទទួលជោគជ័យ ឬជ័យជម្នះនៅទីបញ្ចប់។

**ឆ. តួអង្គ**

តួអង្គច្រើននិយាយអំពី មនុស្ស សត្វ រុក្ខជាតិ កម្លាំងក្រៅខ្លួន មានទេវតា ព្រះឥន្ទ យក្ស អារក្សអ្នកតា...។

**ជ. ទីកន្លែងរឿង**

ទីកន្លែងរឿងគឺមិនបានកំណត់ច្បាស់លាស់ឡើយ ពោលគឺយោងទៅតាមស្ថានភាពនិងប្រភពរឿងនីមួយៗដូចជា ស្ថានភាពភូមិសាស្ត្រមនុស្សរស់នៅ ឋានទេវតា ទីកន្លែងអស្ចារ្យ ជាដើម។ ភាគច្រើនទីកន្លែងមាននៅក្នុងភូមិស្រុកតំបន់និងខេត្តក្នុងប្រទេសកម្ពុជា។

**២.១. ប្រភេទអក្សរសិល្ប៍ប្រជាប្រិយ**

- **គេចែកអក្សរសិល្ប៍ប្រជាប្រិយជាបីប្រភេទគឺៈ**
  - **តំណាលកថាប្រជាប្រិយ**
  - **ពាក្យចួនប្រជាប្រិយ**
  - **របាំប្រជាប្រិយ**

**ក. តំណាលកថាប្រជាប្រិយ**

- **តំណាលកថាប្រជាប្រិយ** គឺជាកម្រងឯកសារដែលឆ្លុះបញ្ចាំងពីរឿងរ៉ាវអតីតរបស់បុព្វបុរសខ្មែរធ្លាប់ត្រូវធម្មជាតិសង្កមធ្វើបាប និងបំណងប្រាថ្នាឱ្យមានសុភមង្គលមានសេរីភាព ព្រមទាំងចង់ឱ្យការស្រមើលស្រមៃបានសម្រេចទៀតផង។តំណាលកថាប្រជាប្រិយ មានដូចជា ទេវកថា ព្រេងកថា និងនិទានកថា។

**១. ទេវកថា** គឺជាប្រភេទតំណាលកថាផ្សេងៗស្តីពីចម្លើយឬការស្រមើលស្រមៃដំបូងបង្អស់របស់មនុស្សលើបាតុភូតធម្មជាតិ។ ទេវកថា គឺត្រូវបានបង្កើតឡើងក្នុងសហគមន៍សម្ងហភាពបុព្វកាល ហើយបានឆ្លុះបញ្ចាំងពីការតស៊ូប្រឆាំងនឹងធម្មជាតិរបស់បុព្វបុរសខ្មែរ ដើម្បីការពារជីវិតពួកកុលសម្ព័ន្ធនៅជំនាន់នោះ។ឧទាហរណ៍ រឿងអ្នកតាទឹកអ្នកតាភ្នំ រឿងសង្គ្រាមគីង្គក់និងតាព្រហ្ម រឿងព្រះពាយ រឿងដើមកំណើតរន្ទះ...។

**១.១. ព្រេងកថា** គឺជារឿងនិទានស្តីពីប្រវត្តិសាស្ត្រ ព្រឹត្តិការណ៍ និងតួអង្គប្រវត្តិសាស្ត្រ។ មួយវិញទៀត ព្រេងកថា ក៏ច្រើនតែរៀបរាប់ទាក់ទងនឹងពិធីផ្សេងៗ ប្រពៃណី ទំនៀមទម្លាប់ ការគោរពបូជា...។

**+ប្រភេទព្រេងកថា**

-ព្រេងកថាទាក់ទងនឹងការកកើតទឹកដីៈ ព្រះថោងនាងនាគ

-ព្រេងកថាទាក់ទងនឹងការកសាងទឹកដីៈ ភ្នំប្រុសភ្នំស្រី

-ព្រេងកថាទាក់ទងនឹងការការពារទឹកដី៖ អ្នកតាឃ្លាំងមឿង

**១.២. និទានកថា**

**និទានកថាប្រជាប្រិយ** ជារឿងដែលនិយាយពីសង្គមចាប់តាំងពីទម្រង់ទំនាស់សម័យដើមរហូតមកដល់ក្រោយៗជាទំនាស់វណ្ណៈក្នុងសង្គមទៅតាមពេលវេលានិងទីកន្លែង។

+**និទានកថាប្រជាប្រិយចែកជា៖**

-**និទានកថាអស្ចារ្យ៖** រឿងមនុស្សលោក រឿងបុរសជីកក្ដាម...

-**និទានកថាសត្វ៖** រឿងត្មាតបោកស្ដេចដំរីស...

-**និទានកថាសង្គម៖** រឿងបុរសចាក់ស្មុគ..

-**និទានកថាសំណើច៖** រឿងម៉ៅស្វិត...។

**ខ. ពាក្យចួនប្រជាប្រិយ**

ពាក្យចួនប្រជាប្រិយ ជាប្រភេទពាក្យដែលមានវាក្យសព្ទនិងផ្ទុកទៅដោយចំណាប់ចុងចួនរណ្ដំណែងណង បង្កប់ទៅដោយខ្លឹមសារអប់រំយ៉ាងជ្រាលជ្រៅ។

- **ពាក្យចួនប្រជាប្រិយមានប្រភពមកពី៖**

-ពលកម្មផលិតកម្ម

-សង្គម

-មនោសញ្ចេតនា

- ពាក្យចួនប្រជាប្រិយមានដូចជា៖

**+ពាក្យចួនប្រជាប្រិយដែលទាក់ទងនឹងការងាររបស់កសិករ និងការធ្វើសង្គ្រាម មានដូចជា៖**

-ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ

-ធ្វើស្រែឱ្យទាន់ក្ដៅដី ចង់ស្រីទាន់ក្ដៅចិត្ត

**+ពាក្យចួនប្រជាប្រិយដែលទាក់ទងនឹងការតស៊ូ ព្យាយាមក្នុងសង្គម មានដូចជា៖**

-តក់ៗពេញបំពង់ ធុងៗកន្លះក្រហែត

-ចេះពីរៀន មានពីរក

-ចេះឱ្យគេកោត ឆោតឱ្យគេអាណិត

-ឃ្លានឆ្ងាញ់ ស្រឡាញ់ល្អ

-នៅមិននៅ ទៅយកជ័រញ្ចៀទៅភ្លៀតភ្លៀក

**+ពាក្យចួនប្រជាប្រិយដែលទាក់ទងនឹងការជិះជាន់របស់អ្នកមានអំណាចបុណ្យសក្ដិមកលើអ្នកក្រីក្រ មានដូចជា៖**

-កូនអ្នកក្រធ្វើទាហាន កូនអ្នកមានធ្វើកុង្ស៊ីយ៍ កូនមន្ត្រីទៅបរទេស

-ជន្លេនមិនដែលខ្ពើមដី មន្ត្រីមិនដែលខ្ពើមប្រាក់

-ពូជស្តៅតែងល្វីង ពូជស្លែងតែងពុល

-ដាំចេកដូង ដាំស្លាជូនអង្គការ ខ្លួនឯងធ្វើមាត់ស្ទេញ

-ទុកមិនចំណេញ ដកចេញមិនខាត

-ជយោ! បដិវត្តន៍ដ៏ត្រឹមត្រូវ រុះផ្ទះស្បូវទៅនៅក្នុងព្រៃ

- **ពាក្យចូនប្រជាប្រិយមានដូចជា**
  - សុភាសិត
  - ចម្រៀងប្រជាប្រិយ
  - ពាក្យបណ្តៅ

**១. សុភាសិត** គឺជាកម្រងពាក្យពេចន៍ទាំងឡាយណា ដែលបុព្វបុរសយើងបង្កើតឡើងតាមរយៈបទពិសោធន៍នានា ដែលធ្លាប់បានជួបប្រទះ ដើម្បីជាប្រយោជន៍ផ្តល់ជាគតិ សម្រាប់អប់រំទូន្មានដល់មនុស្សជំនាន់ក្រោយឱ្យមានសេចក្តីសុខ និងការរីកចម្រើនជាលំដាប់ក្នុងជីវិត។

- **សុភាសិតមានប្រភពមកពីមជ្ឈដ្ឋានដូចជាៈ**

-ជីវភាពរស់នៅរបស់មហាជន

-ប្រភេទផ្សេងៗនៃនិទានកថាប្រជាប្រិយ

-អក្សរសិល្ប៍ចំណារ។

- **សុភាសិតបានបកស្រាយនូវបញ្ហារបស់មនុស្សគ្រប់ស្រទាប់វណ្ណៈ មានដូចជាៈ**

**+សុភាសិតបកស្រាយពីការព្យាយាមអត់ធ្មត់**

-តក់ៗពេញបំពង់

-សន្សឹមៗកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា

-ខឹងខំអត់ ខ្សត់ខំរក

-កុំកួចចិត្តនឹងវាសនា កុំតវ៉ានឹងព្រហ្មលិខិត។

**+សុភាសិតបកស្រាយពីភាពសាមគ្គីផ្ទៃក្នុង**

-សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់

-ចង្កឹះមួយបាច់ កាច់មិនបាក់

-សូវស្លាប់ខ្លួន កុំឱ្យស្លាប់ជាតិ

-សម្តីញុះញង់ នាំឱ្យបាត់បង់សាមគ្គី

**+សុភាសិតបកស្រាយពីការងារកសិកម្ម**

-ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ

-កុំដាក់ស្រូវ នូវផ្លូវដំរី
-ធ្វើស្រែទាន់ក្ដៅដី ចង់ស្រីទាន់ក្ដៅចិត្ត
**+សុភាសិតបកស្រាយពីការសិក្សាអប់រំ**
-ចេះដប់ មិនស្មើអ្នកប្រសប់មួយ
-ជាងមិនកើត បន្ទោសដែក
-គ្រូកាច សិស្សខូច
-គ្នាច្រើនអន្សមខ្លោច គ្នាដូចស្រមោចអន្សមឆៅ
-ចេះឯង ឱ្យក្រែងចេះគេ
-ចង់ចេះឱ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កាយកភ្លើងដុតគល់
-រៀនហើយ រៀនទៀត
-គោបាត់ទើបធ្វើរបង ពេលប្រឡងទើបខំរៀន
**+សុភាសិតបកស្រាយពីការលោភលន់**
-លួចគេវាគ្រាន់ ម្ចាស់គេទាន់វាក្រែល
-ទន្លេដប់ មិនស្កប់សមុទ្រមួយ
-ជន្លេនមិនដែលខ្ទើមដី មន្ត្រីមិនដែលខ្ទើមប្រាក់
-មួយរៀលក៏គ្រាន់ មួយពាន់ក៏គ្រប់
-លួចគេធ្លាប់ដៃ ដេកថ្ងៃធ្លាប់ភ្នែក
**+សុភាសិតបកស្រាយពីការឈឺចាប់**
-កើតមួយជាតិ ជាតុមួយចាន
-អ្នកមានកុំអាលអរ អ្នកក្រកុំទាន់ភ័យ
-ដង្កូវចេញពីសាច់ឯង
-ទឹកឡើងត្រីស៊ីស្រមោច ទឹកហាចស្រមោចស៊ីត្រី
-ចុះទឹកក្រពើ ឡើងលើខ្លា ចូលផ្សារប៉ូលិស
**+សុភាសិតបកស្រាយពីសកម្មភាពក្នុងសង្គម**
-ខឹងគោ ទៅវាយរទេះ
-ចិត្តល្អ ក្រមិយូរ
-ភ្នែកមួយ ភ្នែកដប់
-ទូកទៅ កំពង់នៅ
-ក្ដៅស៊ីរាក់ ត្រជាក់ស៊ីជ្រៅ

-កុំបោះសន្ទូច រំលងភ្នំ
-ក្រមុំសាបដូចទឹកទន្លេ ប្រពន្ធគេឈ្ងុយដូចដូងដុត
-ផ្កាប់បំពង់ រង់ចាំទឹកភ្លៀង
-ក្រមុំដណ្ដឹងម្ដាយ មេម៉ាយដណ្ដឹងចិត្ត
-កុំខ្វើកតាមខ្យល់ កុំខ្វល់តាមស្រី...។

- ន័យនៃសុភាសិត មានពីរយ៉ាងគឺ អត្ថានុរូប ឬន័យចំ និងអត្ថបដិរូប ឬន័យធៀប។

**-អត្ថានុរូប ឬន័យត្រង់** គឺជាការអប់រំដោយផ្ទាល់ត្រង់ៗតែម្ដង ដូចជា ចេះពីរៀន មានពីរក កុំធ្វើស្រែប្រវាស់ កុំសង់ផ្ទះចូលគ្នា ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ...។

**-អត្ថបដិរូបឬន័យធៀប** គឺជាការទូន្មានដោយប្រយោលរបស់កវី បណ្ឌិត អ្នកប្រាជ្ញខ្មែរ ដោយការប្រៀបធៀប ដូចជា ងើយស្កក ឱនដាក់គ្រាប់ សាច់មិនបានស៊ីយកឆ្អឹងព្យួរក ទំពក់វាទៅ ទើបញ្ចៅវាមក...។

- **សុភាសិតខ្មែរ មានលក្ខណៈបីយ៉ាងគឺ៖**

**+សុភាសិតមានន័យជាអត្ថបដិរូបឬន័យធៀបសុទ្ធ៖**សុភាសិតនេះចែកចេញជាពីរប្រភេទគឺ:
-សុភាសិតបែបន័យធៀបសុទ្ធខ្លះ អាចមានមួយឃ្លា ឬពីរឃ្លា ហើយឃ្លានីមួយៗសុទ្ធតែមានន័យជាអត្ថបដិរូប ឬន័យធៀបទាំងអស់។ ឧទាហរណ៍៖ កុំអង្គុយលើឈើពុក កុំយកកទៅលអន្ទាក់ ឱនដាក់គ្រាប់ ងើយស្កក ទូកទៅ កំពង់នៅ ជាដើម។
-សុភាសិតបែបន័យធៀបសុទ្ធខ្លះទៀត ក៏អាចមានមួយឃ្លា ឬពីរឃ្លា ហើយឃ្លានីមួយៗសុទ្ធតែមានន័យជាអត្ថបដិរូប ឬន័យធៀបទាំងអស់ដែរ។ ឧទាហរណ៍៖ ទឹកត្រជាក់ត្រីកុំ ត្រីងៀតឆ្លៀតពង កុំហែកទ្រូងឱ្យក្អែកចឹក ជាដើម។

**+សុភាសិតមានន័យជាអត្ថបដិរូប ឬន័យធៀបផង និងន័យជាអត្ថានុរូប ឬន័យត្រង់ផង៖**
សុភាសិតនេះមានពីរឃ្លា ដែលឃ្លាទីមួយនៃសុភាសិតមានន័យជាអត្ថបដិរូប ឬន័យធៀប។ ចំណែកឯឃ្លាទីពីរ មានន័យជាអត្ថានុរូប ឬន័យត្រង់។ ឧទាហរណ៍៖ កុំពត់ស្រឡៅ កុំប្រដៅមនុស្សខូច ក្របីបាត់ទើបធ្វើរបង ជិតប្រឡងទើបខំរៀន ដំដែកទាន់នៅក្ដៅ ប្រដៅមនុស្សទាន់នៅក្មេង...។

**+សុភាសិតមានន័យជាអត្ថានុរូប ឬន័យត្រង់សុទ្ធ៖** សុភាសិតនេះមានពីរឃ្លា ហើយឃ្លាទាំងពីរសុទ្ធតែមានន័យជាអត្ថានុរូប ឬន័យត្រង់ទាំងអស់។ ឧទាហរណ៍៖ ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ កុំធ្វើស្រែប្រវាស់ កុំសង់ផ្ទះចូលគ្នា ជាដើម។

## ២. ចម្រៀងប្រជាប្រិយ

**ចម្រៀងប្រជាប្រិយ** ជាការសម្ដែងពីមនោសញ្ចេតនាខាងក្នុងរបស់ប្រជាកសិករ ដែលពួកគាត់និយមច្រៀងនៅតាមវាលស្រែចម្ការ បន្ទាប់ពីធ្វើការនឿយហត់ ឬក្នុងពិធីបុណ្យទានផ្សេងៗក្នុងទំនុកចម្រៀង

មានការរៀបរាប់អំពីសេចក្តីសប្បាយរីករាយ ទុក្ខសោក ការងារស្រែចម្ការ ទំនៀមទម្លាប់ប្រពៃណី ជាប់ជំពាក់ជាមួយជាតិមាតុភូមិ។

- **ចម្រៀងប្រជាប្រិយ មានដូចជា៖**

**+ចម្រៀងក្នុងពិធីមង្គលការ**

-បទនគររាជ (ប្រើពេលកាត់ខាន់ស្លា)

-បទដាវឯក (ច្រៀងពេលផ្ទឹម)

-ចម្រៀងក្នុងពិធីចូលម្លប់របស់កូនស្រី

**+ចម្រៀងស្តីពីពលកម្ម**

-បទបេះស្លឹកមនមកចិញ្ចឹមដង្កូវនាង

-ចម្រៀងទាក់ទងនឹងការតម្បាញ

-ចម្រៀងនាងបុកស្រូវ

**+ចម្រៀងស្តីពីសកម្មភាពប្រចាំថ្ងៃ**

-ចម្រៀងរិះគន់បារាំង

-ចម្រៀងរិះគន់យកសាសនា

**+ចម្រៀងវីណាគីតិ**

+ចម្រៀងក្នុងពិធីមង្គលការ

-ចម្រៀងបង្ហាញពីមនោសញ្ចេតនា

-ចម្រៀងបង្ហាញពីទឹកចិត្តប្រជាជន

-ចម្រៀងបង្ហាញពីការខកបំណង

២.២. អត្ថរូបនិងអត្ថរសនៃអក្សរសិល្ប៍ប្រជាប្រិយ

- **អត្ថរូប ៖** មានសេចក្តីផ្តើមខ្លីៗ(មិនកំណត់ច្បាស់លាស់) ឧទាហរណ៍ មានរឿងតំណាលថា....កាលពីព្រេងនា យមាន...។ ដំណើររឿងខ្លីៗលើកឡើងពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជារាស្ត្រ ប្រើពាក្យសាមញ្ញ គ្មានប្រើភាសាបាលី សំស្ក្រឹត ងាយស្រួលយល់និងប្រើពាក្យតាមតំបន់នីមួយៗ។
- **អត្ថរស៖**អក្សរសិល្ប៍ប្រជាប្រិយមានតម្លៃពិសេសនៅក្នុងសង្គមខ្មែរតាំងពីអតីតកាលរហូតដល់សម័យបច្ចុប្បន្ននេះដូចជា៖

✓ បម្រើផលប្រយោជន៍ប្រជារាស្ត្រគ្រប់ស្រទាប់វណ្ណៈ

✓ ធ្វើឱ្យសង្គមស្ថិតស្ថេរ និងរីកចម្រើន

✓ បណ្តុះគំនិតឱ្យមនុស្សមានជំនឿលើខ្លួនឯង

✓ លើកឡើងពីគំនិត ពីជីវភាពរស់នៅជាក់ស្តែងដែលមាននៅក្នុងសង្គម។

ជារួមមក ដោយសារអក្សរសិល្ប៍ប្រជាប្រិយផ្ដើមចេញពីពួកមហាជនគ្រប់ស្រទាប់វណ្ណៈ និងបម្រើសេចក្ដីសប្បាយរីករាយនៃមហាជន អប់រំមនុស្សគ្រប់ស្រទាប់គ្រប់វ័យបែបនេះហើយ ទើបអក្សរសិល្ប៍ប្រជាប្រិយត្រូវតែមានអត្ថិភាពនិងមិនអាចខ្វះបាននៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិតថ្នាក់។មិនតែប៉ុណ្ណោះ អក្សរសិល្ប៍ប្រជាប្រិយ ក៏អាចថែរក្សាវប្បធម៌ និងអរិយធម៌ឱ្យបានគង់វង្សស្ថិតស្ថេរទៅអនាគត។

## ៣. អក្សរសិល្ប៍ទំនើប

**អក្សរសិល្ប៍ទំនើប** គឺជាអក្សរសិល្ប៍ដែលឆ្លុះបញ្ចាំងអំពីសង្គមមនុស្ស បញ្ហាជីវភាពរស់នៅរបស់មនុស្សសុទ្ធសាធ ។

នៅប្រទេសកម្ពុជាយើងការសិក្សាអំពីអក្សរសិល្ប៍ទំនើប ទើបតែចាប់ផ្ដើមតាមលក្ខណៈទំនើបនៅក្រោយពេលដែលបារាំងចូលស្រុកខ្មែរ ហើយស្នាដៃអក្សរសិល្ប៍ដែលមានលក្ខណៈទំនើបពេញលេញ បានប្រសូត្រចេញនូវពាក់កណ្ដាលសតវត្សទី ២០ តាមរយៈស្នាដៃរឿង“ សូផាត” (គ.ស ១៩៣៨ ) របស់លោក រីម គីន និងស្នាដៃរឿង “ ទឹកទន្លេសាប” (គ.ស ១៩៤១ ) របស់លោក គឹម ហាក់ ។

- **អក្សរសិល្ប៍ទំនើបចែកជា ៥ ប្រភេទ គឺ**
  - **សន្ទស្សន៍អក្សរសិល្ប៍**
  - **ប្រលោកអក្សរសិល្ប៍**
  - **ទិដ្ឋិអក្សរសិល្ប៍**
  - **នាកដអក្សរសិល្ប៍**
  - **ឧបទេសអក្សរសិល្ប៍**

**ក.សន្ទស្សន៍អក្សរសិល្ប៍** គឺជាស្នាដៃសរសេរសម្រាប់ប្រាប់ បង្ហាញរៀបរាប់ដូចជា៖

• **ពណ៌នាកថា ៖** រៀបរាប់ពីមនុស្ស សត្វ វត្ថុ...។

• **វណ្ណនាកថា ៖** រៀបរាប់អំពីការធ្វើបុណ្យ ការធ្វើដំណើរអំពីខ្យល់ព្យុះ ភ្លើងឆេះផ្ទះ ... ។

• **និទានកថា ៖** រៀបរាប់អំពីអនុស្សាវរីយ៍ ការផ្សងព្រេង ការប្រយុទ្ធ ... ។

• **សារកថា ៖** ជាអត្ថបទមានលក្ខណៈជាសំបុត្រឆ្លើយឆ្លងក្នុងគ្រួសារ រវាងមិត្តភក្តិ ក្នុងបំណង លាតត្រដាងបញ្ហាអ្វីមួយ ។

**ខ.ប្រលោមអក្សរសិល្ប៍** ជាស្នាដៃដែលតែងអំពីវិបត្តិ ទំនាស់ របស់មនុស្ស ដោយប្រើប្រាស់វិធីប្រលោមធ្វើអោយអណ្ដែតអណ្ដូងភ័យស្លុត ញាប់ញ័រ រំភើបខុសពីធម្មតា ដូចជា ៖

•**ព្រេងកថា ៖** អ្នកនិពន្ធប្រឌិតចងក្រងដោយយករឿងរ៉ាវផ្សេងៗដូចជា រឿងឈ្លោះប្រកែកគ្នា រឿងប្រចណ្ឌណែន....មកលើកជាសេចក្ដីតំណាលទូន្មានប្រាប់អនុជន ។

•**វីរកថា ៖** ជារឿងមួយបែបដែលបង្ហាញតួឯកជាវីរជនដែលមានចិត្តតស៊ូអង់អាចក្លាហាន។ ឧទាហរណ៍ រឿងរាមកេរ្តិ៍...។

• **នវកថា** ៖ គេច្រើនតែងរឿង ដែលមាននៅក្នុងព្រឹត្តិការណ៍ថ្មីៗក្នុងជីវភាពសង្គមនាពេលបច្ចុប្បន្ន ។ឧទាហរណ៍ ៖ បញ្ហាកសាងជីវិត សាមគ្គីភាព ... ។

**គ.នាដកអក្សរសិល្ប៍** គឺជាស្នាដៃដែលតែងសម្រាប់យកទៅលេងល្ខោនដូចជា៖

•**នាដ្យកថា**៖ជាអត្ថបទល្ខោនដែលលើកយករឿងវិបត្តិទំនាស់របស់មនុស្សក្នុងសង្គមមនុស្ស នាសម័យណាមួយ មកធ្វើជាប្រធានរឿង ។

•**ហាសកថា**៖ជាអត្ថបទរឿងល្ខោនដែលមានសកម្មភាព និងដំណើររីករាយសប្បាយដោយ កំប្លុកកំប្លែងធ្វើឱ្យសើច ។

•**ទារុណកថា** ៖ ជារឿងល្ខោន ដែលមានសកម្មភាពដំណើររឿងរីករ៉ កំសត់ធ្វើអោយអ្នកអាន អ្នកទស្សនាញាប់ញ័ររន្ធត់ចិត្ត អាណិតអាសូរតួអង្គខ្សោយ ដែលត្រូវតួអង្គខ្លាំងធ្វើបាប ។

**ឃ.ឧបទេសអក្សរសិល្ប៍** ជាអត្ថបទបែបច្បាប់ទូន្មានសម្រាប់ អប់រំប្រដៅណែនាំដូចជា ៖

•**សុភាសិតកថា**៖ជាកម្រងពាក្យពេចន៍ចងក្រងឡើងសម្រាប់និយាយអប់រំ ក្រើនរំលឹក ចំពោះប្រជាជនដោយប្រើវិធីធ្វើឱ្យចេះពិចារណាត្រិះរិះគិត ... ។

ឧទាហរណ៍. " ចេះពីរៀន មានពីរក" ... ។

" លួចគេវាគ្រាន់ ម្ចាស់គេទាន់វាក្រែល"...។

• **ទូន្មានកថា** ៖ ជាច្បាប់អប់រំ ណែនាំប្រជាជនអោយដើរក្នុងផ្លូវល្អ ផ្លូវត្រូវ ។

ឧទាហរណ៍. ច្បាប់ក្រម ។

• **ល្បើកកថា** ៖ អ្នកនិពន្ធច្រើនយកតួអង្គសត្វ រុក្ខជាតិមកដើរតួតំណាងមនុស្ស ។

ឧទាហរណ៍. រ៉ៃ និងស្រមោច ,កូនចៀមនិងឆ្កែចចក...។

• **សុន្ទរកថា** ៖ ជាអត្ថបទសម្រាប់ថ្លែងក្នុងពិធីអ្វីមួយដូចជា ពិធីសម្ពោធ ពិធីបញ្ចប់ការងារ សន្និបាត ...។

**ង.ទិដ្ឋិអក្សរសិល្ប៍** ជាស្នាដៃបែបអត្ថាធិប្បាយឬការបញ្ចេញមតិរបស់អ្នកនិពន្ធ អ្នកសិក្សារិះគន់អក្សរសិល្ប៍ដូចជា ៖

• **អត្ថាធិប្បាយកថា** ៖ គឺអត្ថាធិប្បាយអំពីពាក្យសុភាសិតនានា អំពីគំនិតផ្សេងៗរបស់អ្នកប្រាជ្ញ របស់អ្នកនិពន្ធ... ។

•**សិក្សាកថា** ៖ជាអត្ថបទដែលយើងលើកយកជីវប្រវត្តិស្នាដៃនានា និងគោលគំនិតរបស់ អ្នកនិពន្ធ កវីទស្សនវិទូ ក្នុងសម័យណាមួយមកសិក្សា ។

•**អក្សរសិល្ប៍កថា**៖ គឺជាអត្ថបទដកស្រង់ចេញអំពីរឿងដែលជាស្នាដៃរបស់អ្នកនិពន្ធនាសម័យណាមួយជួនកាលអក្សរសិល្ប៍កថាមានសភាពជាអត្ថបទតាក់តែងខ្លីល្មម អំពីបញ្ហា អ្វីមួយសម្រាប់ធ្វើជា អត្ថបទអំណាន ឬ ធ្វើជាអត្ថបទសរសេរតាមអានជាដើម ។

# ចលនាអក្សរសិល្ប៍

ចលនាអក្សរសិល្ប៍ខ្មែរបែងចែកជា៤គឺ

- ចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម
- ចលនាអក្សរសិល្ប៍ពុទ្ធនិយម
- ចលនាអក្សរសិល្ប៍ខេមរនិយម
- ចលនាអក្សរសិល្ប៍បរទេសនិយម

## អក្សរសិល្ប៍ព្រាហ្មណ៍និយម

**អក្សរសិល្ប៍ព្រាហ្មណ៍និយម** គឺជាអក្សរសិល្ប៍ដែលទទួលឥទ្ធិពលពីព្រាហ្មណ៍សាសនា។រឿងក្នុងគោលព្រាហ្មណ៍និយម គឺជារឿងមានលក្ខណៈអស្ចារ្យ អច្ឆរិយៈ ហួសពីសមត្ថភាពមនុស្សទៀតផង។

ក. គោលគំនិតរបស់អក្សរសិល្ប៍ព្រាហ្មណ៍និយម

**-មហិទ្ធិឫទ្ធិ និងអំណាចរបស់តួអង្គខ្លាំងពូកែ** ជាតួអង្គតំណាងឱ្យអាទិទេព

**-មធ្យោបាយដើម្បីយកឈ្នះ** គឺការធ្វើសង្គ្រាម

**-តួអង្គឯកបុរស** គឺជាកំពូលបុរសខ្លាំងពូកែលើសគេអស់ត្រៃភព

**-តួអង្គអាក្រក់** តំណាងឱ្យសភាវៈអាក្រក់ ដូចពួកយក្ស អសុរៈ ...ជាអ្នកមានកំហុស ហើយត្រូវការផ្តន្ទាទោសពីសំណាក់សភាវៈល្អ ឬតួអង្គអវតាររបស់ព្រះវិស្ណុ នៅទីចុងបញ្ចប់សភាវៈអាក្រក់ត្រូវតែបរាជ័យជានិច្ច។

ខ. លក្ខណៈសម្គាល់អក្សរសិល្ប៍ព្រាហ្មណ៍និយម

**+ការផ្តើមរឿង**

-ការផ្តើមរឿងនៃស្នាដៃអក្សរសិល្ប៍ប្រភេទនេះគឺការបង្ហាញពីឈ្មោះរបស់អាទិទេពទាំងបី ដូចជាព្រះព្រហ្ម ព្រះវិស្ណុ ព្រះឥសូរ និងពិធីបូជាយញ្ញ ឬវិធីផ្សេងៗ។

**+តួរឿង**

**-តួអង្គ៖** ជាអវតារនៃព្រះវិស្ណុមកយាងចាប់កំណើតជាមនុស្ស ជាបុរសអស្ចារ្យនិងជានារីអស្ចារ្យ ឯតួអង្គផ្សេងៗទៀតមាន ឥសី ទេវតា គ្រុឌ ស្វា យក្ស ជាដើម។

**-ដំណើររឿង៖** ច្បាំងមិនចេះចប់មិនចេះហើយប្រកបដោយសិល្ប៍សាស្ត្រអស្ចារ្យ។ ដំណើររឿងមានភាពអច្ឆរិយៈដូចជា ជប ហោះហើរ ប្រោះ ថ្លែងសរ ជ្រែកដី ជាដើម។

**-ទីកន្លែង៖** ព្រៃហេមពាន្ត ក្រុងឰយុធ្យា ស្ថានសួគ៌ ក្រុងបាតាល ស្ថានសិម្ពលី ពោលគឺឋានទាំងបី។

**-ទំនាស់ឬបញ្ហាចោទ៖** កើតឡើងដោយសារវិបត្តិទំនាស់រវាងសភាវៈល្អនិងសភាវៈអាក្រក់ ច្បាំងទាស់ទែងគ្នា មានទាំងទារុណកម្មខាងផ្លូវកាយនិងផ្លូវចិត្ត។

**-ដំណោះស្រាយ៖** ការប្រើសិល្ប៍មន្ត ឫទ្ធិអំណាច សងសឹកធ្វើចម្បាំងនឹងគ្នា ឬហៅថាយុទ្ធវិធី។

**-ស្នេហា៖** អ្នកឈ្នះ ឬអ្នកខ្លាំងទទួលបានស្នេហា។

**-ឧត្តមគតិរឿង៖** អប់រំមនុស្សឱ្យជឿលើអាទិទេព ហើយមានជំនឿថា ទុក្ខសោក ល្អអាក្រក់របស់ខ្លួនបានមកពីអាទិទេពជាអ្នកកំណត់។

**+បញ្ចប់រឿង**

-ការបញ្ចប់រឿងបែបព្រាហ្មណ៍និយម គឺតួអង្គតំណាងអាទិទេព ឬសភាវៈល្អ មានជ័យជម្នះលើសភាវៈអាក្រក់ ដូចជា យក្ស គ្រុឌ  អសុរៈ ជាដើម។

## គ. រឿងដែលស្ថិតនៅក្នុងចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម

-រឿងរាមកេរ្តិ៍

-រឿងមហាភារតៈ

-រឿងរាមាយណៈ

-រឿងកូរសមុទ្រទឹកដោះ

-រឿងវិស្ណុលោក ជាដើម។

## ឃ. គោលសំខាន់នៃសាសនាព្រាហ្មណ៍

ព្រាហ្មណ៍សាសនា ហូរចូលប្រទេសកម្ពុជានិងរីកចម្រើនខ្លាំងនៅសតវត្សទី១នៃគ.ស។

- សាសនាព្រាហ្មណ៍ចែកជាបីសម័យកាលធំៗគឺ

-**សម័យវេទនិយម** (១៥០០ឆ្នាំដល់៥៥០មុនគ.ស)

-**សម័យព្រាហ្មណ៍និយម** (៥៥០ឆ្នាំមុនគ.សដល់សតវត្សទី១០នៃគ.ស)

-**សម័យហិណ្ឌូនិយម** (សតវត្សទី១០នៃគ.សរហូតមក)

## ១. សម័យវេទនិយម

វេទនិយម គឺជាលទ្ធិបុរាណនៅប្រទេសឥណ្ឌាដែលនិយមឱ្យតម្លៃទៅលើគម្ពីរវេទ។

- **គេចែកគម្ពីរវេទជា៤គឺ**

**-ឫគ្វេទ** ជាវេទសំខាន់ជាងគេសម្រាប់សូត្របួងសួងសរសើរដល់ទេវៈដូចជា ព្រះឥន្ទ្រ ព្រះរុទ្រៈ ព្រះវាយុ ព្រះអគ្គិ ព្រះអាទិត្យ ព្រះធរណី ព្រះចន្ទ ព្រះវរុណ ជាដើម។

**-សាមវេទ** គឺសម្រាប់សូត្រសរសើរទេវៈមាន ព្រះឥន្ទ្រ ព្រះយម ព្រះព្រហស្បត្តិ៍ និងទេវៈជាច្រើនទៀត។

**-យជុរវេទ** គឺប្រើសម្រាប់សូត្រក្នុងពិធីបូជាយញ្ញនិងសម្រាប់ពន្យល់ឱ្យចេះធ្វើពិធីបុណ្យសាសនា។

**-អថរវេទ** គឺជាវេទស្តីពីមន្តអាគមគាថា សែកឱ្យអាយុវែង ជាជំងឺ មានទ្រព្យសម្បត្តិ ស្រីស្រឡាញ់ បន្ទន់ចិត្ត បណ្តេញខ្មោច បណ្តេញឧបទ្រពចង្រៃ អំពើអាបធ្មប់ ជាដើម។អត្ថបទវេទចែកចេញជា៤ផ្នែកគឺ៖

**-សំហិតា:** អត្ថបទនិយាយពីការបួងសួង ការបូជា និងការសរសើរទេវៈដែលប្រោសសត្វលោក។

**-ព្រាហ្មណ៍:** អត្ថបទពន្យល់ឱ្យចេះបូជា សូត្រសរសើរ ធ្វើរីតី ធ្វើពិធីបូជាយញ្ញ ប្រើមន្ត។ ក្រៅពីនេះព្រាហ្មណ៍និយាយពី ព្រហ្ម័ន ព្រះព្រហ្ម ព្រាហ្មណ៍ សំសារ(ការកើតស្លាប់)។

**-អារណ្យក:** អត្ថបទពន្យល់ពីការរស់នៅក្នុងព្រៃដូចជា ការប្រព្រឹត្តរបស់អ្នកបួសនៅក្នុងព្រៃ ការប្រព្រឹត្តតឹងរ៉ឹងរបស់តាបស ឬឥសី ការស៊ឹងស្មាធិ៍អប់រំចិត្តឱ្យល្អ ជាដើម។

**-គម្ពីរឧបនិស័ទ:** គឺស្ថិតនៅក្នុងសម័យវេទដែលបានលើកឡើងវិញនូវគម្ពីរទាំងបីខាងលើនិងបទបញ្ញាផ្សេងៗដល់ពួកព្រាហ្មណ៍ដទៃទៀត។ គម្ពីរនេះអធិប្បាយពីការកើត-ស្លាប់របស់មនុស្ស។ ឧបនិស័ទ អត្ថបទនិយាយពីទស្សនៈវិជ្ជា គឺពន្យល់ពីលោក ចិត្ត អាត្ម័ន ព្រហ្ម័ន សំសារ សុខ ទុក្ខ តបៈ យោគៈ ជាដើម។

❖ **គេចែកវណ្ណៈជា៤ប្រភេទគឺ**

**-វណ្ណៈព្រាហ្មណ៍៖** កើតចេញពីព្រះឱស្ឋព្រះព្រហ្ម ជាអ្នកបួសនិងបង្រៀនវេទ ប្រើសម្លៀកបំពាក់ពណ៌ស។

**-វណ្ណៈក្សត្រ៖** កើតចេញពីកំភួនដៃព្រះព្រហ្ម ជាអ្នកចម្បាំងគ្រប់គ្រងនគរ ប្រើសម្លៀកបំពាក់ក្រហម។

**-វណ្ណៈវៃស្ស៖** កើតចេញពីភ្លៅព្រះព្រហ្ម ជាអ្នកធ្វើការរកស៊ីទូទៅ ប្រើសម្លៀកបំពាក់ពណ៌លឿង។

**-វណ្ណៈសូទ្រ៖** កើតចេញពីជើងព្រះព្រហ្ម ជាអ្នកបម្រើគេ ប្រើសម្លៀកបំពាក់ពណ៌ខ្មៅ។

## ២. សម័យព្រាហ្មណ៍និយម

ព្រាហ្មណ៍និយម គឺជាលទ្ធិបន្តពីវេទនិយម ពួកព្រាហ្មណ៍បានកែច្នៃទស្សនៈទ្រឹស្តីឱ្យកាន់តែល្អឡើងស្របតាមសម័យនិងតាមចំណង់ចំណូលចិត្តមនុស្ស ហើយបានរៀបចំចងក្រងទស្សនៈទ្រឹស្តីទាំងនោះឱ្យមានក្បួនខ្នាតត្រឹមត្រូវដើម្បីប្រកួតប្រជែងនឹង«ពុទ្ធនិយម»។ គម្ពីរថ្មីនោះមានឈ្មោះថា**ច្បាប់មនុ** កើតចន្លោះឆ្នាំ២០០ឆ្នាំមុនគ.សនិង២០០ឆ្នាំក្រោយគ.សជាអំណោយរបស់អាទិទេព។តាមលទ្ធិព្រាហ្មណ៍និយមគេបែងចែកពិភពលោកជាបីផ្នែកគឺ ឋានទេវតា ឋានមនុស្ស និងឋានបាតាល។ ចំណែកមនុស្សលោកគេចែកចេញជាពីរប្រភេទគឺ មនុស្សអស្ចារ្យនិងមនុស្សធម្មតា។ មួយវិញទៀតព្រាហ្មណ៍សាសនាគេគោរពលើអាទិទេពទាំងបីគឺ ព្រះព្រហ្ម ជាអ្នកបង្កើតលោក ព្រះវិស្ណុ ជាអ្នកគ្រប់គ្រងថែរក្សាលោក បែងភាគជាអវតារដើម្បីជួយមនុស្ស និងព្រះសិវៈឬឥសូរ ជាអ្នកបំផ្លាញលោក។

❖ បើតាមសាសនាព្រាហ្មណ៍អវតារព្រះវិស្ណុមាន១០គឺ៖

**-មត្ស្យ:** ជាត្រី

**-កូម៌:** ជាអណ្តើក

**-វរាហ:** ជាជ្រូកព្រៃ

**-នរសិង្ហ:** ជាមនុស្សសិង្ហ

**-វាមន:** ជាមនុស្សតឿ

**-បរសុរាម:** ជាព្រះរាមកាន់ពូថៅ

**-ព្រះរាម** ជាមនុស្សទេវៈ

**-ក្រឹស្ណ:** ជាមនុស្សខ្មៅ

**-ពុទ្ធ:** ជាព្រះពុទ្ធ

**-កល្កិន:** ជាមនុស្សសេះ។

- ក្នុងសម័យព្រាហ្មណ៍ មានពហូសូត្រវិជ្ជាដូចជា៖

**-វេយ្យាករណ៍:** ចងក្រងជាភាសាសំស្ក្រឹត បាលី ក្បួនសំខាន់កើតនៅក្នុងសតវត្សទី៤មុនគ.ស។

**-វចនានុក្រមវិទ្យា:** វចនានុក្រមដែលមានអាយុច្រើនជាងគេ កើតនៅក្នុងរវាងសតវត្សទី៤និងទី៦នៃគ.ស។

**-កាព្យវិទ្យា:**សំខាន់កើតតាំងពីសតវត្សទី១០មុនគ.ស(រៀបរាប់ពីចំណាប់ចួន ចំនួនព្យាង្គ ចំនួនឃ្លា...)។

**-នាដ្យវិទ្យា:** គឺជាវិជ្ជាសិក្សាសិល្បៈល្ខោន។

**-អត្ថវិទ្យា:** ជាវិជ្ជាសិក្សាពីប្រយោជន៍ តម្លៃ ឬគោលដៅដែលជាអាយុជីវិតនៃប្រទេសជាតិដូចជានយោបាយ សេដ្ឋកិច្ច ការគ្រប់គ្រង សង្គមកិច្ច ការសិក្សាអប់រំជាដើម។ អត្ថបទនេះកើតឡើងប្រហែលសតវត្សទី៦មុនគ.ស។

**-កាមវិទ្យា:** ជាវិជ្ជាពន្យល់ពីស្នេហា។ គេជួបប្រទះវិជ្ជានេះនៅមុនសតវត្សទី៧ អត្ថបទនេះទាក់ទងនឹងពហូសូត្រវិជ្ជា គឺមហាភារតៈ បុរាណៈ តន្ត្រៈ រាមាយណៈ ធម្មសាស្ត្រៈ។

### ៣. ហិណ្ឌូនិយម

ហិណ្ឌូនិយមគឺបានបន្តពីសម័យព្រាហ្មណ៍និយម គឺឱ្យតម្លៃលើស្រុតិឬគម្ពីរវេទទាំង៤ អត្ថបទផ្សេងៗរបស់ពួកព្រាហ្មណ៍ ពហូសូត្រ កម្រងទស្សនៈទាំង៦ វណ្ណៈទាំង៤ ការបែងចែកជីវិតអាស្រមទាំង៤ នៅអនុវត្តតែគេប្រើពាក្យ កាមៈ អថ៌ៈ ធម៌ៈ មោក្សៈជំនួសវិញ និងឱ្យតម្លៃលើទស្សនៈឯកទេវនិយមផង ពហុវេទនិយមដូចសម័យមុនដែរ។

# អក្សរសិល្ប៍ពុទ្ធនិយម

**អក្សរសិល្ប៍ពុទ្ធនិយម** ជាអក្សរសិល្ប៍ទាំងឡាយណាដែលបានទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា។

**១. ប្រភេទអក្សរសិល្ប៍ពុទ្ធនិយម**

**+អក្សរសិល្ប៍ពុទ្ធនិយមចែកជាបីប្រភេទគឺ៖**

-អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ

-អក្សរសិល្ប៍ពុទ្ធនិយមក្លាយ

-អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ។

- **អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ** ជាអត្ថបទអក្សរសិល្ប៍ទាំងឡាយណាដែលមាននៅក្នុងទសជាតក ដែលជាគម្ពីរដ៏សំខាន់នៅក្នុងព្រះពុទ្ធសាសនា ឬជារឿងរបស់ព្រះពោធិសត្វនិងការកសាងបារមីដើម្បីត្រាស់ជាព្រះពុទ្ធ។

**+រឿងទាំងដប់មានដូចជា៖**

**-តេមិយជាតក៖** បំពេញនេក្ខកម្មបារមី គឺការសាងផ្នួស

**-មហាជនកជាតក៖** បំពេញវិរិយបារមី គឺការព្យាយាម

**-សុវណ្ណសាមជាតក៖** បំពេញមេត្តាបារមី គឺការប្រណី

**-នេមិរាជជាតក៖**បំពេញអធិដ្ឋានបារមីគឺការតាំងចិត្តដ៏ប្រសើរ

**-មហោសថជាតក៖** បំពេញបញ្ញាបារមី គឺការដឹងសេចក្ដីពិត

**-ភូរិទត្តជាតក៖** បំពេញសីលបារមី គឺការវៀរចាកអំពើអាក្រក់

**-ចន្ទកុមារជាតក៖** បំពេញខន្តីបារមី គឺការអត់ធន់

**-នារទព្រហ្មជាតក៖** បំពេញឧបេក្ខាបារមី គឺតាំងចិត្តជាកណ្ដាល

**-វិធុរជាតក៖** បំពេញសច្ចបារមី គឺការប្រកាន់សេចក្ដីពិត

**-វេស្សន្តរជាតក៖** បំពេញទានបារមី គឺការឱ្យទាន។

រឿងបែបពុទ្ធនិយមសុទ្ធ ឬពិត គឺអ្នកនិពន្ធបានដកស្រង់ចេញពីគម្ពីរទសជាតក គឺជាប្រវត្តិរបស់ព្រះសក្យមុនីគោតមបរមសម្ពុ

ទ្ធក្នុង១០ជាតិ ហើយចែកក្នុងរឿងទាំង១០។ រឿងនេះបានផ្ដល់នូវដំបូន្មាននិងភាសិតសំខាន់ៗប្រកបដោយឧត្តមគតិ។ ម្យ៉ាងវិញទៀត អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ ក៏ជាអក្សរសិល្ប៍ដែលមានលក្ខណៈទេវនិយម មានអន្តរាគមន៍ពីព្រះឥន្ទ តែមិនឆ្លុះបញ្ចាំងពីតថភាពក្នុងសង្គមឡើយ។ ឧទាហរណ៍ រឿងមហាវេស្សន្តរជាតក គឺជា រឿងដែលបានបង្ហាញពីព្រឹត្តិការណ៍សំខាន់ តាមរយៈការបំពេញទានបរិច្ចាគទាំងប្រាំយ៉ាងរបស់តួអង្គព្រះពោធិសត្វ ព្រះនាមព្រះវេស្សន្តរ ដែលមាន៖

- ធនបរិច្ចាគ គឺលះបង់ទ្រព្យសម្បត្តិ
- អង្គបរិច្ចាគ គឺលះបង់សរីរាង្គកាយណាមួយ
- ជីវិតបរិច្ចាគ គឺលះបង់អាយុជីវិត
- បុត្តបរិច្ចាគ គឺលះបង់កូន
- ភរិយាបរិច្ចាគ គឺលះបង់ប្រពន្ធ។

ចំពោះសង្គមមនុស្សជាក់ស្តែងមិនមានទេ ពោលគឺមានតែព្រះទើបមានចិត្តដូច្នេះ។

- **អក្សរសិល្ប៍ពុទ្ធនិយមក្លាយ** សំដៅលើអត្ថបទអក្សរសិល្ប៍ទាំងឡាយដែលមាននៅក្នុងគម្ពីរបញ្ញាសជាតក គឺរឿងទាំង៥០ជាតិរបស់ព្រះពោធិសត្វ។អក្សរសិល្ប៍ពុទ្ធនិយមក្លាយ បានបរិយាយទាក់ទងនឹងទ្រឹស្តីព្រះពុទ្ធសាសនាតិចតួច ហើយពុំស្ថិតនៅក្នុងគម្ពីរពុទ្ធវចនៈទេ ឬគម្ពីរព្រះត្រៃបិដក។

**+រឿងបញ្ញាសជាតក មាន៥០គឺៈ**

| | |
|---|---|
| ១. រឿងសមុទ្រឃោសៈ | ២រឿងសធនកុមារ |
| ៣. រឿងសុធនុ | ៤. រឿងរតនប្បជោត |
| ៥. រឿងសិរីវិបុលកិត្តិ | ៦. រឿងវិបុលរាជ |
| ៧. រឿងសរីចូឌាមណី | ៨. រឿងចន្ទរាជ |
| ៩. រឿងសព្វមិត្ត | ១០. រឿងសិរីជរសេដ្ឋី |
| ១១រឿងសព្វសិទ្ធិ | ១២. រឿងទុលកបណ្ឌិត |
| ១៣. រឿងអាទិត្តរាជ | ១៤. រឿងទុកមានិក |
| ១៥. រឿងមហាសុរសេន | ១៦. រឿងសុវណ្ណកុមារ |
| ១៧. រឿងធនករាជ | ១៨. រឿងវិរិយបណ្ឌិត |
| ១៩. រឿងធម្មសោណ្ឌក | ២០.រឿងសុទស្សនមហារាជ |
| ២១. រឿងវត្តង្គុលីរាជ | ២២.រឿងបោរាណកបិបុរនរិន |
| ២៣. រឿងធម្មិកបណ្ឌិត | ២៤. រឿងមហាបុរិស |
| ២៥. រឿងធម្មរាជ | ២៦. រឿងនរជីវ |
| ២៧. រឿងស្សរូប | ២៨.រឿងមហាបទុមកុមារ |
| ២៩. រឿងភណ្ឌាគារកុមារ | ៣០. រឿងពហុលគាវី |
| ៣១. រឿងសេតបណ្ឌិត | ៣២. រឿងបុបរាជ |
| ៣៣. រឿងពារាណសិរាជ | ៣៤.រឿងព្រហ្មឃោសរាជ |
| ៣៥. រឿងទេវទុក្ខកុមារ | ៣៦. រឿងសលភ |

៣៧. រឿងសិទ្ធិសារកុមារ	៣៨. រឿងនរជីវ
៣៩. រឿងអតិទេវរាជ	៤០. រឿងសិម្ពនាទ
៤១. រឿងសុវណ្ណសង្ខរាជកុមារ	៤២. រឿងសុរព្ព
៤៣. រឿងទេវន្ទ	៤៤. រឿងសុវណ្ណកច្ឆប
៤៥. រឿងសុបិនកុមារ	៤៦. រឿងសុវណ្ណវង្ស
៤៧. រឿងសិទ្ធិសារ	៤៨. រឿងសិរីសរាជកុមារ
៤៩. រឿងចន្ទឃាត	៥០. រឿងសទ្ធាតិស្សចក្កវត្តិ

- **អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ** សំដៅដល់អត្ថបទអក្សរសិល្ប៍មួយប្រភេទដែលពុំមាននៅក្នុងគម្ពីរទសជាតកឬបញ្ញាសជាតក នោះទេ។

+អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ មានដូចជា៖

-រឿងកាកី

-រឿងចៅស្រទបចេក

-រឿងក្រុងសុភមិត្រ

-រឿងចម្ប៉ាថោង

-រឿងទិព្វសង្វារ

-រឿងហង្សយន្ត

-រឿងមរណមាតា

-រឿងជិនវង្ស

-រឿងរតនាវង្ស

-រឿងសុវណ្ណវង្ស

-រឿងទេវន្ទ

-រឿងស័ង្ខសិល្ប៍ជ័យ

-រឿងភោគកុលកុមារ..........។

## ២. លក្ខណៈសម្គាល់អក្សរសិល្ប៍ពុទ្ធនិយម

- **លក្ខណៈសម្គាល់របស់អក្សរសិល្ប៍ពុទ្ធនិយមគឺ៖**

**+ផ្ដើមរឿង**

-ការធ្វើបទនមស្ការរំលឹកគុណព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។

-និទានទាក់ទងកាលព្រះពុទ្ធគង់នៅវត្តណាមួយ ហើយទ្រង់បានសម្ដែងរឿងកាលពីអតីតជាតិរបស់ព្រះអង្គ។

**+តួរឿង**

**-តួអង្គ៖** តួអង្គឯកប្រុស គឺជាព្រះពោធិសត្វ រីឯតួអង្គឯកស្រី គឺជាកន្សែសារពេជ្រដែលជាគូនឹងព្រះពោធិសត្វ ចំណែកតួអង្គបន្ទាប់ បន្សំ មានមនុស្ស សត្វ យក្ស ទេវតា...។

**-ដំណើររឿង៖** គឺយកទស្សនៈកម្មផល ឬកម្មពៀរ មកបង្ហាញ ដោយមានលក្ខណៈឆ្លងជាតិកំណើត ពោលគឺអំពើពីអតីតជាតិហុចផលសម្រាប់បច្ចុប្បន្នជាតិ ឯអំពើនៃបច្ចុប្បន្នជាតិហុចផល ឱ្យមនុស្សទៅអនាគតជាតិ។

**-ទីកន្លែង៖** នគរពារាណសី ក្រុងសាវត្ថី នគរមិថិលា តក្កសិលា ព្រៃហេមពាន្ត ឋានសួគ៌ ឋានមនុស្ស ឋាននរក ជាដើម។

**-ស្នេហា៖** ស្នេហារវាងព្រះពោធិសត្វនិងកន្សែសារពេជ្រជាស្នេហាបរិសុទ្ធ។

**-ចំណោទបញ្ហាឬទំនាស់៖** ទំនាស់រវាងព្រះពោធិសត្វ និងរាជសម្បត្តិ មាតាបិតា មហេសី បុត្រ ញាតិប្រជានុរាស្ត្រ ...។

**-ដំណោះស្រាយ៖** ដោះស្រាយបញ្ហាដោយសន្តិវិធី ធម៌អហិង្សា។

**-គំនិតអប់រំឬឧត្តមគតិរឿង៖**

-អប់រំមនុស្សឱ្យជឿលើកម្មផល ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់

-អប់រំមនុស្សឱ្យរក្សាសីល

-អប់រំមនុស្សឱ្យជឿជាក់លើខ្លួនឯង

-អប់រំមនុស្សឱ្យព្យាយាមតស៊ូ គ្មានចិត្តលោភលន់

-អប់រំមនុស្សឱ្យដោះស្រាយបញ្ហាដោយសន្តិវិធី

-អប់រំមនុស្សឱ្យស្រឡាញ់សន្តិភាព

-អប់រំមនុស្សឱ្យយកបញ្ញាមកធ្វើជាដំណោះស្រាយបញ្ហា...។

**+បញ្ចប់រឿង៖**មានការសជាតិតួអង្គឯកបានសម្រេចជោគ ជ័យតាមបំណងរបស់ខ្លួន និងបានជួបជុំគ្រួសារវិញក្រោយពីព្រាត់ប្រាសគ្នា។

## ៣. អត្ថន័យនៃអក្សរសិល្ប៍ពុទ្ធនិយម

អត្ថន័យដ៏សំខាន់នៅក្នុងអក្សរសិល្ប៍ពុទ្ធនិយម គឺបង្ហាញពីជំនឿ និងជីវិតរបស់ព្រះពោធិសត្វ។ ចំពោះអក្សរសិល្ប៍ពុទ្ធនិយមក្លាយ រឿងនិងទំនាស់ឆ្លុះបញ្ចាំងពីរឿងនិទានក្នុងគម្ពីរបញ្ញាសជាតក ដែលមានលក្ខណៈមនុស្ស លក្ខណៈសង្គម និងលក្ខណៈប្រជាជន ជាងអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ ដែលមានលក្ខណៈទេវៈ។ការដោះស្រាយបញ្ហាក្នុងអក្សរសិល្ប៍ពុទ្ធនិយមក្លាយ តួអង្គគឺពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន តែនៅក្នុងអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ គេឃើញមានអន្តរាគមន៍ ពីទេវៈ ដូចជាព្រះឥន្ទជាដើម។

## ៤. ទស្សនៈសំខាន់នៃពុទ្ធសាសនា

ពុទ្ធសាសនាគឺជាសាសនាមនុស្សនិយម រូបមន្តដំបូងបំផុតរបស់ព្រះពុទ្ធសាសនា គឺចតុរារិយសច្ចៈ ឬ អរិយសច្ចៈទាំង៤។ ពុទ្ធសាសនាមានគោលដៅស្វែងយល់រកហេតុផលនៃសេចក្តីសុខ និងសេចក្តីទុក្ខ។ អរិយសច្ចៈបួនយ៉ាងគឺ

- **ទុក្ខសច្ចៈ** គឺអ្វីគ្រប់យ៉ាងគឺជាទុក្ខ។
- **សមុទយសច្ចៈ** គឺហេតុនាំឱ្យកើតទុក្ខ(អវិជ្ជានិងតណ្ហា)
- **និរោធសច្ចៈ** គឺការរំលត់ទុក្ខ(បំបាត់អវិជ្ជានិងតណ្ហា)
- **មគ្គសច្ចៈ** គឺផ្លូវរំលត់ទុក្ខ(មានអង្គ៨ឬមគ្គ៨គឺ
    - ✓ **សម្មាទិដ្ឋិ** (ការយល់ឃើញត្រូវ)
    - ✓ **សម្មាសង្កប្ប** (ការត្រិះរិះត្រូវ)
    - ✓ **សម្មាវាចា** (វាចាត្រូវ)
    - ✓ **សម្មាកម្មន្ត** (ការងារត្រូវ)
    - ✓ **សម្មាអាជីវ** (ការចិញ្ចឹមជីវិតត្រូវ)
    - ✓ **សម្មាវាយាម** (ការព្យាយាមត្រូវ)
    - ✓ **សម្មាសតិ** (ការរលឹកត្រូវ)
    - ✓ **សម្មាសម្មាធិ** (ការតម្កល់ចិត្តត្រូវ)។

**៥. អត្ថរសនៃអក្សរសិល្ប៍ពុទ្ធនិយម**

តម្លៃនៃអក្សរសិល្ប៍ពុទ្ធនិយម ស្តែងចេញនូវទស្សនៈរបស់ព្រះពុទ្ធគឺធ្វើល្អ បានល្អ ធ្វើអាក្រក់ បាន អាក្រក់ និងអប់រំសីលធម៌ព្រះពុទ្ធសាសនា។អត្ថរសនៃអក្សរសិល្ប៍ពុទ្ធនិយមអាចចែកចេញជា៖

- **បច្ចេករស៖** ប្រើប្រាស់ពាក្យកាព្យនិងរៀបចំដំណើររឿងឱ្យមានភាពអណ្តែតអណ្តូងឱ្យអ្នកអាន រំភើបចង់តាមដានដំណើររឿង។
- **វិសេសរស៖** បានបង្ហាញពីតម្លៃល្អ តម្លៃអាក្រក់ វីរភាពរបស់តួអង្គ សកម្មភាពអស្ចារ្យ សកម្មភាព តស៊ូរបស់តួអង្គ សោកនាដកម្មនិងសកម្មភាពរស់រវើកនិងកំប្លែងដើម្បីឱ្យអ្នកអានរីករាយ។
- **សព្វរស៖** ឆ្លុះបញ្ចាំងពីតថភាពសង្គមក្នុងសង្គម និងជីវភាពប្រចាំថ្ងៃ លក្ខណៈអច្ឆរិយ និង កុសលរសដែលជាតម្លៃនៃការទូន្មានប្រៀនប្រដៅ។

# អក្សរសិល្ប៍ខេមរនិយម

- **អក្សរសិល្ប៍ខេមរនិយម** គឺជាស្នាដៃអក្សរសិល្ប៍ដែលបានបង្ហាញពីផ្នត់គំនិត ជំនឿ ប្រពៃណី ទំនៀមទម្លាប់ មុខរបរ បញ្ហាសង្គម និងជីវភាពរស់នៅរបស់ប្រជាជនខ្មែរក្នុងសម័យកាលនីមួយៗ។

## ១. អត្ថន័យនៃអក្សរសិល្ប៍ខេមរនិយម

គោលបំណងសំខាន់បំផុតនៃអក្សរសិល្ប៍ខេមរនិយម បានបង្ហាញពីជីវភាពជាក់ស្ដែងរបស់មនុស្សក្នុងសង្គមស្របទៅតាមវប្បធម៌អរិយធម៌។មួយវិញទៀតស្នាដៃអក្សរសិល្ប៍ខេមរនិយម ទាក់ទងទៅនឹងសង្គមបរិយាកាសខ្មែរគឺទំនៀមទម្លាប់ ប្រពៃណី ប្រវត្តិសាស្ត្រ ភូមិសាស្ត្រខ្មែរជាដើម។ដំណើររឿងកើតឡើងនៅក្នុងភូមិស្រុក ឬទីកន្លែងណាមួយដោយមានទំនាក់ទំនងទៅនឹងការប្រកបអាជីវកម្មរបស់ខ្មែរដែលជារឿងតថៈ។ចំពោះបញ្ហាទំនាស់គឺកើតឡើងនៅក្នុងជីវភាពរបស់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ ដែលតែងតែកើតមានក្នុងសង្គមដូចជា ទំនាស់រវាងខ្លួនឯង ឬទំនាស់ជាមួយអ្នកដទៃ ទំនាស់រវាងខ្លួនឯងនិងគ្រួសារ ទំនាស់រវាងអ្នកដទៃនិងគ្រួសារខ្លួន ទំនាស់រវាងខ្លួនឯងនិងសង្គមជាដើម។

ការដោះស្រាយបញ្ហានៅក្នុងអក្សរសិល្ប៍ខេមរនិយមគឺតួអង្គពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន ជម្នះផ្លូវកាយ ផ្លូវចិត្តដើម្បីផ្ចាញ់ឧបសគ្គក្នុងសង្គមឬធម្មជាតិ។

## ២. អត្ថរូបនៃអក្សរសិល្ប៍ខេមរនិយម

អក្សរសិល្ប៍ខេមរនិយម ច្រើនតែសរសេរជាអត្ថបទរឿងប្រលោមលោក ជាពាក្យកាព្យ ពាក្យរាយក្ដីក៏ជារឿងកម្សាន្តឬអានកម្សាន្តកែអផ្សុក តែបង្កប់គតិអប់រំទូន្មានទៅរកផ្លូវរីកចម្រើន។ភាសាក្នុងរឿងច្រើនយកពាក្យអ្នកស្រុកជាន់កណ្ដាល ជាន់ខ្ពស់ ឬប្រជាជនសាមញ្ញ ដោយពុំសូវយកភាសាបាលីសំស្ក្រឹតដែលពិបាកអានមកប្រើឡើយ។

## ៣. លក្ខណៈសម្គាល់នៃអក្សរសិល្ប៍ខេមរនិយម

### ក. ផ្ដើមរឿង

-ការផ្ដើមរឿងក្នុងស្នាដៃអក្សរសិល្ប៍បែបខេមរនិយមគឺមិនកំណត់ ឬពុំមានឯកភាពគ្នារវាងអ្នកនិពន្ធនោះទេ ផ្ទុយពីចលនាអក្សរសិល្ប៍ពុទ្ធិនិយម និងព្រាហ្មណ៍និយម ដែលមានក្បួនខ្នាតច្បាស់លាស់។

### ខ. ដំណើររឿង

-អ្នកនិពន្ធលើកដំណើររឿងទាក់ទងនឹងជីវភាពរស់នៅ ទំនៀមទម្លាប់ ប្រពៃណី សាសនា របស់ប្រជាជនខ្មែរ។មួយវិញទៀត អ្នកនិពន្ធច្រើនតែនិទានខ្លួនឯង គឺការនិទានតាមបែបបុរសទី៣។

-**តួអង្គ** ៖ តួអង្គមានចរិតលក្ខណៈដូចមនុស្សធម្មតាទូទៅនៅក្នុងសង្គមជាក់ស្ដែងដែលមានសកម្មភាពដូចជា ចេះស្រឡាញ់ ចេះស្អប់ ចេះខឹង យំ សើច រីករាយ ប្រច័ណ្ឌជាដើម។

-**ទីកន្លែង៖** អ្នកនិពន្ធនិយាយអំពីស្រុកភូមិ ឬទីតាំងភូមិសាស្ត្រនៅក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍ដូចជា រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ អ្នកនិពន្ធបានលើកយកទីកន្លែងដូចជា បាត់ដំបង ភ្នំពេញ ជាដើម។

-**បញ្ហាចោទឬទំនាស់៖** បញ្ហាទំនាស់គឺកើតឡើងដូចនៅក្នុងសង្គមខ្មែរជាក់ស្តែង ដូចករណី ទំនាស់ស្នេហា ទំនាស់គ្រួសារ ទំនាស់វណ្ណៈ ទំនាស់ដណ្តើមទ្រព្យសម្បត្តិ ...។

-**ដំណោះស្រាយ៖** គឺការដោះស្រាយបញ្ហាឬទំនាស់ ជម្លោះដោយពឹងផ្អែកលើសមត្ថភាពខ្លួនឯង និងស្របតាមស្ថានភាពសង្គម គ្មានការជួយអន្តរាគមន៍ពីអាទិទេពអ្វីឡើយ។

-**បញ្ហាស្នេហា៖** គឺជាស្នេហារបស់មនុស្សពិតៗជាក់ស្តែងដែលកើតឡើងពីចិត្ត អារម្មណ៍របស់តួអង្គឯកប្រុសនិងស្រី ដែលតំណាងឱ្យមនុស្សគ្រប់ប្រភេទក្នុងសង្គម ហើយវាជាស្នេហាគ្មានព្រំដែន។ ចំពោះស្នេហាគឺមានជួបគ្នា (រឿងកុលាបប៉ៃលិន តួអង្គបានរស់នៅជួបជុំគ្នា) ឬព្រាត់គ្នា (រឿងទុំទាវ រឿងផ្កាស្រពោន តួអង្គព្រាត់គ្នា) អាស្រ័យទៅលើកត្តាសង្គម និងកត្តាជីវភាពជាដើម។

### គ. បញ្ចប់រឿង

-ការបញ្ចប់រឿងគឺមានភាពខុសៗគ្នាទៅតាមសិល្បវិធីរបស់អ្នកនិពន្ធ ឬគ្មានការឯកភាពគ្នាឡើយ។

## ៤. អត្ថរសនៃអក្សរសិល្ប៍ខេមរនិយម

តម្លៃរបស់ស្នាដៃអក្សរសិល្ប៍ខេមរនិយម ស្តែងចេញពីការឆ្លុះបញ្ចាំងនូវតថភាពជាក់ស្តែង ការអប់រំសីលធម៌និងស្មារតីជាតិនិយមពិតៗ តាមរយៈភាពប៉ិនប្រសប់របស់អ្នកនិពន្ធ។

## ៥. រឿងដែលស្ថិតនៅក្នុងចលនាអក្សរសិល្ប៍ខេមរនិយម

- រឿងផ្កាស្រពោន
- រឿងសូផាត
- រឿងគូលីកំណែន
- រឿងកុលាបប៉ៃលិន
- រឿងមាលាដួងចិត្ត
- រឿងទុំទាវ
- រឿងគ្រូបង្រៀនស្រុកស្រែ
- រឿងតេជោយ៉តជាដើម។

# អក្សរសិល្ប៍បរទេសនិយម

## ១. និយមន័យ

**អក្សរសិល្ប៍បរទេសនិយម** គឺជាអត្ថបទអក្សរសិល្ប៍ដែលបានលើកយកទំនៀមទម្លាប់របស់បរទេសមកបង្ហាញដែលផ្ទុយពីផ្នត់គំនិត និងទំនៀមទម្លាប់ខ្មែរ។

## ២. អត្ថន័យនៃអក្សរសិល្ប៍បរទេសនិយម

គោលនិយមនេះសំដៅដល់គោលគំនិតផ្សេងៗដែលពុំស្របតាមលទ្ធិព្រាហ្មណ៍សាសនា ពុទ្ធសាសនា ឬជាទំនៀមទម្លាប់សុទ្ធសាធរបស់ខ្មែរ ដែលធ្លាប់មានមកនោះទេ។

ប្រទេសយើងទើបតែមានគោលនិយមនេះកើតឡើងក្នុងពេលដែលស្រុកទេសត្រូវធ្លាក់ខ្លួនគ្រាំគ្រា ហើយបរទេសនាំយកគោលគំនិតពីស្រុកគេមកផ្សព្វផ្សាយក្នុងប្រទេសយើង។

សព្វថ្ងៃនេះគេឃើញនៅសល់គោលនិយមនេះជាច្រើនដូចជា ផ្នែកសុជីវធម៌ សម្លៀកបំពាក់ សិល្បៈ ការរាំរែក..។

## ៣. លក្ខណៈសម្គាល់អក្សរសិល្ប៍បរទេសនិយម

### ក. ផ្តើមរឿង

-ការរៀបរាប់បែបសេរី ដោយពុំមានលក្ខណៈឯកភាពគ្នាដូចរឿងព្រាហ្មណ៍និយមនិងពុទ្ធនិយមឡើង។

### ខ. តួរឿង

-ប្រភព៖ មានប្រភពមកពីបស្ចឹមប្រទេស។

-លំហូរចូល៖ ចូលបដិសន្ធិក្នុងប្រវត្តិអក្សរសិល្ប៍ខ្មែរចាប់ពីសម័យអាណានិគមបារាំងរហូតមក។

-អ្នកនិពន្ធ៖ ជាជនជាតិខ្មែរ ជាសិស្ស ជានិស្សិត ជាបញ្ញវន្ត ដែលបានទៅសិក្សារៀនសូត្រនៅបរទេស ពិសេសនៅអឺរ៉ុបនិងអ្នកនិពន្ធមួយចំនួនទៀតដែលបានសិក្សារៀនសូត្រនៅសាលាទំនើបក្នុងស្រុក។

-តួអង្គ៖ ជាមនុស្សខ្មែរ មានឈ្មោះខ្មែរ និងមានលាយឡំឈ្មោះបែបបរទេស ឬបរទេសខ្លះៗ។ និយមស្លៀកពាក់បែបអឺរ៉ុប ស៊ីវិល័យ ឆើតឆាយ...។ អាកប្បកិរិយាចាប់ដៃ ឱបថើប ជាដើម។

-ភាសា៖ រចនាបថនិពន្ធជាភាសាខ្មែរ ប៉ុន្តែលាយឡំ ឬបង្ហាញច្រើនគួរកត់សម្គាល់ផងដែរនូវពាក្យបរទេសថ្មីៗដែលមកពីបស្ចឹមប្រទេស។ឧទាហរណ៍ វីឡា កាត ដេម៉ុងត្រេ...។

-ទីកន្លែង៖ ដំណើររឿងបានប្រព្រឹត្តទៅក្នុងស្រុក ភូមិប្រទេសខ្មែរ ឬប្រព្រឹត្តទៅនៅតាម បា ក្លឹប ជាដើម។

-បញ្ហាទំនាស់៖ កើតឡើងរវាងមនុស្ស សង្គម លើបញ្ហាមិនចុះសម្រុងគ្នាដូចជាបញ្ហាវណ្ណៈ របៀបរបបរស់នៅជាដើម។

-បញ្ហាស្នេហា៖ ជាស្នេហារបស់មនុស្សខ្មែរ ប៉ុន្តែនិយមតាមបែបទអឺរ៉ុប។

-ដំណោះស្រាយ៖ ពឹងផ្អែកលើសមត្ថភាពខ្លួនឯង និងផ្សារភ្ជាប់ជាមួយការអនុវត្តច្បាប់រដ្ឋជាដើម។

-ឧត្តមគតិរឿង៖ បណ្តុះគំនិតមនុស្សឱ្យចេះពិចារណាលើលក្ខណៈទំនើបនិយមរបស់បរទេស។

**គ. បញ្ចប់រឿង**

-តួអង្គអាចរស់នៅជួបជុំគ្នា ឬសម្រេចជោគជ័យក្នុងជីវិត។

-តួអង្គអាចស្លាប់ បែកបាក់គ្នា ឬបរាជ័យក្នុងដំណើរជីវិត ដោយអនុលោមតាមដំណើររឿង និងសិល្បវិធីរបស់អ្នកនិពន្ធ។

**៤. រឿងដែលស្ថិតនៅក្នុងចលនាអក្សរសិល្ប៍បរទេសនិយមគឺ**

- រឿងជីវិតឥតន័យ (និពន្ធដោយ សុទ្ធ ប៉ូលីន)
- រឿងថៅកែចិត្តចោរ (និពន្ធដោយ ពៅ យូឡេងនិងអ៊ុំ ឈឺន)

## លក្ខណៈអក្សរសិល្ប៍

- លក្ខណៈអក្សរសិល្ប៍ខ្មែរ មានដូចជា៖
  - លក្ខណៈជាតិ
  - លក្ខណៈមនុស្ស
  - លក្ខណៈប្រវត្តិ
  - លក្ខណៈវណ្ណៈ
  - លក្ខណៈសង្គម
  - លក្ខណៈបក្ស
  - លក្ខណៈប្រជាជន។

**១. លក្ខណៈជាតិ**

**លក្ខណៈជាតិ** គឺជាលក្ខណៈពិសេសរបស់ជាតិមួយ ដែលលេចធ្លោរខុសពីជាតិដទៃ តាមរយៈជំនឿ សាសនា ទំនៀមទម្លាប់ ប្រពៃណី សិល្បៈ ភាសា វប្បធម៌ ជាដើម។

- គេចាត់ទុកអក្សរសិល្ប៍ដែលមានលក្ខណៈជាតិ ជាស្នាដៃទាំងឡាយណាដែលបានទ្រទ្រង់ព្រលឹងជាតិឱ្យស្ថិតស្ថេរជាអមតៈ ដើម្បីបណ្តុះគំនិតស្រឡាញ់ អភិរក្ស ការពារ និងអភិវឌ្ឍអរិយធម៌របស់ជាតិ។ ឧទាហរណ៍ ក្នុងរឿងរាមកេរ្តិ៍ រឿងទុំទាវ រឿងសព្វសិទ្ធិ រឿងមាលាដួងចិត្ត....អ្នកនិពន្ធបានពណ៌នាពីទេសភាពធម្មជាតិ ផ្កា ផ្លែឈើ ម្រឹគីម្រឹគា ទន្លេ ស្ទឹង ជាដើម សុទ្ធសឹងបញ្ជាក់ឱ្យបានឃើញច្បាស់នូវលក្ខណៈជាតិដែលមាននៅលើទឹកដីខ្មែរ។
- **ឧទាហរណ៍៖ លក្ខណៈជាតិក្នុងរឿងទុំទាវ៖**
  - **អ្នកនិពន្ធបានប្រើប្រាស់ភាសាជាតិ** និងទម្រង់កំណាព្យខ្មែរសម្រាប់តាក់តែងស្នាដៃ។

- **ឈ្មោះតួអង្គ** ជាឈ្មោះបែបខ្មែរ ដូចជា ទុំ ទាវ នោ អរជូន ម៉ឺនងួនព្រះរាមាជើងព្រៃ...។
- **បង្ហាញពីជីវភាពរស់នៅ**របស់ប្រជារាស្ត្រខ្មែរនាសម័យលង្វែក ពោលគឺប្រជារាស្ត្រខ្មែរប្រកបមុខរបរធ្វើស្រែចម្ការ លក់ដូរ។
- **របបគ្រប់គ្រង៖** សង្គមខ្មែរនាសម័យលង្វែក ស្តេចផែនដី ស្តេច ត្រាញ់ មេគ្រួសារ។
- **ការទុកដាក់កូនចៅឱ្យមានគូស្រករ** ដោយប្រើទស្សនៈ«នំមិនធំជាងនាឡិ»។
- **ជំនឿ** គឺការជឿលើការទស្សន៍ទាយ ពាក្យទំនាយគ្រូ។
- **ទំនៀមទម្លាប់ ប្រពៃណី** គឺកូនប្រុសបួសរៀននៅវត្ត រីឯកូនស្រីដល់អាយុពេញវ័យត្រូវចូលម្លប់ និងមានបង្ហាញពីពិធីស្តីដណ្តឹង ពិធីរៀបអាពាហ៍ពិពាហ៍ ជាដើម។
- **ប្រជារាស្ត្រគោរពព្រះពុទ្ធសាសនា** ទុំនិងពេជ្រ ប្រជារាស្ត្រចូលចិត្តស្តាប់លោកស្មូត្រនិងទេសនា ហើយក៏មានឥទ្ធិពលព្រាហ្មណ៍សាសនាផងដែរ ដូចករណីទុំសូត្រមន្តអាគម សារិកាលិនថោង។
- **ទីតាំងភូមិសាស្ត្រ** មានខេត្តបាភ្នំ ខេត្តត្បូងឃ្មុំ ពោធិ៍ជើងខាល វត្តវិហារធំ...។

- **លក្ខណៈវិនិច្ឆ័យស្នាដៃមានលក្ខណៈជាតិគឺ៖**
- ជាស្នាដៃបង្ហាញនិងបំផុសទឹកចិត្តស្នេហាជាតិមាតុភូមិ ស្រឡាញ់ប្រពៃណីជាតិ បំផុសស្មារតីតស៊ូប្រកបដោយថាមពល
- ជាស្នាដៃបណ្តុះស្មារតីជាតិនិយម បណ្តុះឆន្ទៈឯករាជ្យ
- បង្ហាញតួអង្គដែលពោរពេញទៅដោយចិត្តសាស្ត្រ និងលក្ខណៈជាតិ
- អ្នកនិពន្ធចេះប្រើប្រាស់យ៉ាងប៉ិនប្រសប់នូវឃ្លោងឃ្លា ពាក្យពេចន៍របស់ជាតិ និងចេះបង្កើតសិល្ប៍រូបារម្មណ៍។

## ២. លក្ខណៈមនុស្ស

**អក្សរសិល្ប៍ដែលមានលក្ខណៈមនុស្ស** គឺជាការលើកយកបញ្ហាមនុស្សមកចោទនិងដោះស្រាយនៅក្នុងដំណើររឿង ទោះបីអ្នកនិពន្ធលើកយកតួអង្គសត្វក្តី ធម្មជាតិក្តី តួអង្គអច្ឆរិយក្តី ក៏តួអង្គទាំងនោះនៅតែជាតំណាងមនុស្សនៅក្នុងសង្គមដែរ។លក្ខណៈមនុស្សក្នុងអក្សរសិល្ប៍ គឺជាលក្ខណៈរួមទូទៅរបស់មនុស្សដូចជា ការសើចសប្បាយ រីករាយ ប្រច័ណ្ឌ ច្រណែន ខឹង ស្អប់ យំ ជាដើម។

- **លក្ខណៈមនុស្សរាស្តែងឱ្យឃើញតាមរយៈដូចជា៖**
  - សកម្មភាព
  - ទង្វើ
  - អាកប្បកិរិយា
  - ពាក្យសម្តី

- ចិត្តគំនិតរបស់តួអង្គក្នុងរឿង។

❖ លក្ខណៈមនុស្សក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរគឺ៖

**-ទន្សាយ** តំណាងឱ្យមនុស្សមានប្រាជ្ញា ស្រឡាញ់យុត្តិធម៌

**-ខ្លា** តំណាងឱ្យមនុស្សកាចសាហាវ

**-ក្រពើ** តំណាងឱ្យមនុស្សរមិលគុណ

**-ក្រុងរាពណ៍** តំណាងឱ្យមនុស្សផ្តាច់ការ អត្តនោម័តិ អាជ្ញានិយម

**-ហនុមាន** តំណាងឱ្យមនុស្សមានសមត្ថភាព ស្មោះត្រង់

**-ស្រមោច** តំណាងឱ្យមនុស្សឧស្សាហ៍ ព្យាយាម តស៊ូ

**-រំ** តំណាងឱ្យមនុស្សខ្ជិលច្រអូស មិនចេះសន្សំសំចៃ

**-ចចក** តំណាងឱ្យមនុស្សសម្បូរល្បិច។

❖ **លក្ខណៈមនុស្សរបស់តួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍គឺ**

-ព្រះរាមយំសោកនឹករឭកនាងសីតា

-ព្រះរាមខឹងប្រច័ណ្ឌនាងសីតាជាមួយក្រុងរាពណ៍

-ព្រះរាមឱ្យនាងសីតាដើរលុយភ្លើង ដើម្បីបញ្ជាក់ពីភាពបរិសុទ្ធ

-ព្រះរាមឈ្លោះជាមួយកូនក្មេង គឺកូនរបស់ខ្លួនឯង រាមលក្សណ៍ និងជបលក្សណ៍។

**៣. លក្ខណៈវណ្ណៈ**

**លក្ខណៈវណ្ណៈ** គឺជាលក្ខណៈអក្សរសិល្ប៍មួយប្រភេទដែលតាមរយៈនោះអ្នកនិពន្ធលើកយកបញ្ហាការតស៊ូវណ្ណៈ ការការពារឧត្តមគតិ ចរិត គោលបំណងនៃវណ្ណៈណាមួយមកបង្ហាញ។

❖ **លក្ខណៈវណ្ណៈក្នុងអក្សរសិល្ប៍ស្តែងឡើងតាមរយៈ៖**

**-លក្ខណៈវណ្ណៈស្តែងឡើងតាមរយៈរូបារម្មណ៍៖** ឧទាហរណ៍នៅក្នុងដំណើររឿងកុលាបប៉ៃលិន អ្នកអានអាចស្រមៃឃើញពីស្ថានភាពនៃគ្រួសារចៅចិត្រនិងគ្រួសាររបស់លោកហ្លួងរតនសម្បត្តិ។

**-លក្ខណៈវណ្ណៈស្តែងឡើងតាមរយៈតួអង្គ៖** តួអង្គសំខាន់ៗគឺ សម្តែងចេញនូវលក្ខណៈវណ្ណៈ តាមរយៈភាសានិយាយ មនោសញ្ចេតនា និងសកម្មភាពដែលនាំឱ្យយើងឃើញច្បាស់នូវលក្ខណៈ វណ្ណៈ។ ក្នុងអត្ថបទខ្លះ អ្នកនិពន្ធបានឱ្យតួអង្គយំសោក ស្តាយស្រណោះដល់ទ្រព្យសម្បត្តិ អំណាច រាជបល្ល័ង្ក ដែលត្រូវបាត់បង់ទៅឬសប្បាយរីករាយនៅពេលបានឡើងសោយរាជ្យ។ឧទាហរណ៍ រឿងផ្កាស្រពោន នាងចូ ប្រាប់យាយនួនថា នាយណៃស៊ត ជាកូនអ្នកមាន។ រីឯក្នុងរឿងព្រះវេស្សន្តរ លក្ខណៈវណ្ណៈគឺស្តែងឱ្យឃើញតាមរយៈអន្តរាគមន៍ពីទេវៈចំពោះតួអង្គនៃព្រះពោធិសត្វ និងកន្សែ សារពេជ្ជ ដែលកំពុងជួបវិបត្តិសោកសៅ។

**-លក្ខណៈវណ្ណៈស្ដែងឡើងតាមរយៈអ្នកនិពន្ធ៖** អ្នកនិពន្ធបានទទួលឥទ្ធិពលពីសង្គមដែលខ្លួនបានរស់នៅ បញ្ហាវណ្ណៈជិតដាមនៅក្នុងអារម្មណ៍ មនោសញ្ចេតនារបស់អ្នកនិពន្ធ។ ទោះបីជាអ្នកនិពន្ធចង់ចៀសវាងពីបញ្ហាវណ្ណៈ ក៏នៅតែមានជិតដាមនូវលក្ខណៈវណ្ណៈនៅក្នុងស្នាដៃដែរ។ ក្នុងសង្គមខ្មែរមាន អ្នកមាន និងអ្នកក្រ នាំឱ្យស្នាដៃអក្សរសិល្ប៍ក៏មានពីរដែរ គឺអក្សរសិល្ប៍ការពារអ្នកមាន និងអក្សរសិល្ប៍ការពារអ្នកក្រ។ ឧទាហរណ៍៖ លោក ញ៉ុក ថែម តាក់តែងរឿងកុលាបប៉ៃលិន ក្នុងគោលបំណងផ្សះផ្សារវាងអ្នកមាននិងអ្នកក្រ។

## ៤. លក្ខណៈសង្គម

**លក្ខណៈសង្គម** គឺជាលក្ខណៈមួយប្រភេទដែលតាមរយៈនោះ អ្នកនិពន្ធបានលើកយកបញ្ហាសង្គមមនុស្សក្នុងសម័យ ណាមួយមកបង្ហាញ ចោទនិងដោះស្រាយក្នុងដំណើររឿង។

ឧទាហរណ៍៖ រឿងទុំទាវ គឺបានបង្ហាញឱ្យឃើញពីរបៀបរបបគ្រប់គ្រង និងច្បាប់ទម្លាប់មួយចំនួនរបស់សង្គមខ្មែរនាសម័យលង្វែកគឺ៖

**-អំណាចរបស់ព្រះរាជា** ៖ ព្រះរាជាជាអ្នកគ្រប់គ្រង កាត់ក្ដី ដឹកនាំប្រទេស។

**-អំណាចស្ដេចត្រាញ់៖** ស្ដេចត្រាញ់មានអំណាចគ្រប់គ្រង ជំនុំ  ជំរះក្ដីនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

«ឧកញ៉ាអរជូនមាំមួនពេក  ធម្មតាក្រោមមេឃទាបជាងភ្នំ

មានឫទ្ធិអំណាចឥតជំនុំ កាប់ចាប់វាយដំពុំប្រណី»។

**-អំណាចមេគ្រួសារ៖** អំណាចគ្រួសារស្ថិតនៅលើមេគ្រួសារឬឪពុកម្ដាយ«នំមិនធំជាងនាឡិ»។

ដូច្នេះរឿងទុំទាវ បង្ហាញពីលក្ខណៈសង្គមបែបរាជាធិបតេយ្យ និងប្រកាន់ប្រពៃណី«នំមិនធំជាងនាឡិ»។

## ៥.លក្ខណៈប្រវត្តិ

លក្ខណៈប្រវត្តិ គឺជាលក្ខណៈមួយដែលស្នាដៃអក្សរសិល្ប៍ ទាក់ទងនឹងសម័យកាល ឬព្រឹត្តិការណ៍ខ្លះៗដែលកើតមាននៅក្នុងប្រវត្តិសាស្ត្រ។ ប៉ុន្តែយើងត្រូវយល់ថា អក្សរសិល្ប៍ពុំដូចគ្នានឹងប្រវត្តិសាស្ត្រដែលមាននាទីកត់ត្រានូវរឿងរ៉ាវៗឬព្រឹត្តិការណ៍ផ្សេងៗបានកើតឡើងក្នុងសង្គមនីមួយៗនោះឡើយ។

**អក្សរសិល្ប៍ដែលមានលក្ខណៈប្រវត្តិ** គឺជាអក្សរសិល្ប៍ដែលបានលើកយកពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្លះៗនាសម័យកាលណាមួយមកបង្ហាញ។ រាល់ព្រឹត្តិការណ៍ដែលកើតឡើងក្នុងសង្គមត្រូវបានស្មេរកត់ត្រាក្នុងគម្ពីរប្រវត្តិសាស្ត្រ។ រីឯអ្នកនិពន្ធគ្រាន់តែលើកយកព្រឹត្តិការណ៍សំខាន់ៗទាំងនោះមករៀបរៀងជាស្នាដៃអក្សរសិល្ប៍។

**ឧទាហរណ៍៖**

-រឿងភូមិតិរច្ឆាន តាមប្រវត្តិសាស្ត្រ រឿងនេះកើតនៅសម័យអាណានិគមបារាំង។

-រឿងអ្នកតាឃ្លាំងមឿង តាមប្រវត្តិសាស្ត្រ រឿងនេះកើតឡើងនៅសម័យលង្វែក។

-រឿងទុំទាវ តាមប្រវត្តិសាស្ត្រ រឿងនេះបានកើតឡើងនាសម័យលង្វែក។

❖ **ភាពខុសគ្នារវាងប្រវត្តិវិទ្យានិងលក្ខណៈប្រវត្តិគឺ៖**

-អក្សរសិល្ប៍មានលក្ខណៈប្រវត្តិ គ្រាន់តែមានដំណើររឿងរ៉ាវខ្លះដែលទាក់ទងនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនាសម័យកាលណាមួយប៉ុណ្ណោះ។

-ប្រវត្តិវិទ្យា ជាមុខវិជ្ជាមួយដែលអធិប្បាយអំពីប្រវត្តិសាស្ត្រ ឬព្រឹត្តិការណ៍ជាក់ស្ដែងទាក់ទងនឹងជីវភាពរស់នៅរបស់ប្រជាជន ឬការគ្រប់គ្រងនៅសម័យកាលណាមួយ។

## ៦. លក្ខណៈបក្ស

លក្ខណៈបក្ស គឺជាលក្ខណៈមួយដែលផ្ដើមចេញពីលក្ខណៈវណ្ណៈ ដែលជាសារជាតិ ជាក្រិតក្រមរបស់សង្គម និងជនជាតិចាប់តាំងពីពេលដែលមនុស្សមានការបែងចែកជាពួក ជាក្រុម ទៅតាមទស្សនៈ គោលការណ៍ លទ្ធិឬមនោគមវិជ្ជា តែក្រុមនីមួយៗ។ចំណុចពិសេសៗនៃលក្ខណៈបក្សមាន៖

- បំផុសស្មារតី ឧត្ដមគតិស្នេហាជាតិ មាតុភូមិរបស់ប្រជាកសិករ
- បំផុសស្មារតី បញ្ចុះបញ្ចូលអ្នកអាន អ្នកស្ដាប់ អ្នកទស្សនាឱ្យលង់ជំនឿទៅលើបក្សណាមួយ
- ផ្សព្វផ្សាយឥទ្ធិពលដឹកនាំនិងសកម្មភាពរបស់បក្សក្នុងការកសាងមាតុភូមិ
- ជាស្នាដៃបម្រើនយោបាយនិងបម្រើមាគ៌ារបស់បក្ស ការពារផលប្រយោជន៍ដោយផ្សារភ្ជាប់នឹងផលប្រយោជន៍ជាតិ។

## ៧. លក្ខណៈប្រជាជន

**អក្សរសិល្ប៍មានលក្ខណៈប្រជាជន** គឺជាអក្សរសិល្ប៍ដែលយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ទាំងជីវភាព សម្ភារៈ ភាសា ស្មារតី ផ្នត់គំនិត សតិអារម្មណ៍ ឧត្ដមគតិ មនោសញ្ចេតនា ចំណង់ចំណូលចិត្ត បំណងប្រាថ្នារបស់ប្រជាជន ការពារផលប្រយោជន៍របស់ប្រជាជន និងប្រឆាំងនឹងការកេងប្រវ័ញ្ចពីវណ្ណៈជិះជាន់។ ឧទាហរណ៍ រឿងធនញ្ជ័យ រឿងអាខ្វាក់អាខ្វិន រឿងអាឡេវ រឿងបងថ្លៃនិងប្អូនថ្លៃ...។

## ៨. លក្ខណៈអន្តរជាតិ

លក្ខណៈអន្តរជាតិ គឺជាលក្ខណៈមួយរបស់អក្សរសិល្ប៍ បន្ទាប់ពីមានលក្ខណៈជាតិរួចហើយ បន្ទាប់មកត្រូវបានបរទេសយកមករៀនសូត្រផ្សព្វផ្សាយនៅក្នុងអន្តរជាតិរបស់គេ។

**អក្សរសិល្ប៍ដែលមានលក្ខណៈអន្តរជាតិ** គឺជាស្នាដៃអក្សរសិល្ប៍ដែលមានលក្ខណៈជាតិ ហើយត្រូវបានសង្គមជាតិទទួលស្គាល់ថាជាអត្ថបទមានតម្លៃ ទ្រទ្រង់ឱ្យវប្បធម៌ អរិយធម៌របស់ជាតិ។ បន្ទាប់មកត្រូវបានបរទេសយកទៅសិក្សាផ្សព្វផ្សាយនៅក្នុងសង្គមរបស់ពួកគេ គឺនៅពេលនោះហើយដែលអក្សរសិល្ប៍មានលក្ខណៈសកល គឺលក្ខណៈអន្តរជាតិ។

**ឧទាហរណ៍**

-រឿងទុំទាវ របស់អ្នកនិពន្ធ ភិក្ខុ ងួន សោម

-រឿងរាមាយណៈ របស់អ្នកនិពន្ធ វាល្មិកិ
-រឿងចចកនិងកូនចៀម របស់អ្នកនិពន្ធ ឡា ហ្វុងតែន
-រឿងជនកំណាញ់ របស់អ្នកនិពន្ធ ម៉ូលីយែរ
-រឿងសង្គ្រាមនិងសន្តិភាព របស់អ្នកនិពន្ធ តុលស្តូយ
-រឿងទុរគតជន របស់អ្នកនិពន្ធ វិចទ័រ ហ៊ុយហ្គោ

## ប្រភពអក្សរសិល្ប៍

❖ **អក្សរសិល្ប៍មានប្រភពមកពី៖**

**-សភាវៈកម្សាន្ត** ៖ ដោយឆ្លងកាត់ការនឿយហត់ នាំឱ្យមនុស្សចង់កម្សាន្តកើតឡើងឯកឯង។

**-សភាវៈគតិអនុកម្ម(ការត្រាប់តាម)** ៖ ជាការចម្លងតាមស្នាដៃអក្សរសិល្ប៍ដែលមានរួចមកហើយ មកពិពណ៌នា បង្ហាញ គូរ ឆ្លាក់ ឱ្យឃើញឡើងវិញ។

**-សាសនា** ៖ ជាទម្រង់សតិអារម្មណ៍មួយ ដែលត្រួសត្រាយផ្លូវមនុស្សតាំងពីយូរណាស់មកហើយ។

**-ពលកម្ម** ៖ សាក្សីនៃស្នាដៃអក្សរសិល្ប៍និងសិល្បៈ ដែលបានបន្សល់ទុកដោយសារពលកម្ម មានដូចជា រឿងនិទាន ឧបករណ៍ពលកម្ម ក្បាច់ចម្លាក់តាមប្រាសាទ និងរូងភ្នំទាំងឡាយ គ្រឿងអលង្ការ ជាដើម។

## ភារកិច្ចអក្សរសិល្ប៍

❖ **អក្សរសិល្ប៍មានភារកិច្ចដូចជា៖**

**-កែប្រែមនុស្ស៖** អក្សរសិល្ប៍រួមចំណែកជួយជំរុញការអប់រំ ធ្វើឱ្យសង្គមមានការផ្លាស់ប្តូរពីភាពអន់ថយទៅភាពរុងរឿង ការកែប្រែប្រព័ន្ធគ្រប់គ្រងសង្គម នយោបាយ ទម្លាប់ខុសឆ្គង របៀបរបបរស់នៅដែលពុំសមស្របនឹងកាលៈទេសៈសង្គមឱ្យល្អប្រសើរឡើង។

**-អភិវឌ្ឍលក្ខណៈសម្បត្តិរបស់មនុស្ស៖** អក្សរសិល្ប៍ជួយបណ្តុះមនុស្សឱ្យមានសមត្ថភាព មានសុភវិនិច្ឆ័យ ចេះវិភាគដោះស្រាយបញ្ហា ស្រឡាញ់យុត្តិធម៌ សិទ្ធិសេរីភាព គុណធម៌ ភាពស្អាតស្អំ និងធ្វើឱ្យមនុស្សខ្ពង់ខ្ពស់ជាងសត្វតិរច្ឆាន។

# វត្ថុបំណងអក្សរសិល្ប៍

អក្សរសិល្ប៍មានវត្ថុបំណងគឺ ស្វែងរកសោភ័ណ សច្ចៈ និងសុខៈ។

❖ ចំពោះទស្សនៈផ្សេងៗអំពីសុខៈគឺ៖

-**ទស្សនៈទី១** ដើម្បីសម្រេចសុខៈបាន មនុស្សត្រូវគោរពបន់ស្រន់អាទិទេព ធ្វើសមាធិបំពេញមោក្ស(ការរំដោះ) ដើម្បីផ្ដាច់អាត្ម័នចេញពីវដ្ដសង្សារឱ្យវិលទៅជួបអាត្ម័ន។

-**ទស្សនៈទី២** ដើម្បីសម្រេចសុខៈ មនុស្សត្រូវប្រមូលទ្រព្យសម្បត្តិឱ្យបានច្រើន ដោយគ្រប់វិធី ទោះបីសង្គមជាតិត្រូវធ្លាក់ដុនដាបយ៉ាងណាក៏ដោយ។

-**ទស្សនៈទី៣** សុខៈពុំស្ថិតនៅលើការបន់ស្រន់ ការគោរពអាទិទេព ឬការប្រមូលទ្រព្យសម្បត្តិឱ្យបានច្រើននោះទេ សុខៈសំដៅលើការអភិវឌ្ឍសង្គមនោះឯង។ ដូច្នេះអក្សរសិល្ប៍ដែលបណ្ដុះការងារនិយមអភិវឌ្ឍន៍សង្គមហៅថា អក្សរសិល្ប៍មានបំណងស្វែងរកសុខៈ សម្រាប់សង្គមមនុស្ស។

+**សុខៈ**ក្នុងអក្សរសិល្ប៍មានទំនាក់ទំនងនឹងសង្គមស្ទើរតែគ្រប់វិស័យដូចជា ប្រវត្តិសាស្ត្រ សាសនា សិល្បៈ បច្ចេកទេស សីលធម៌ នយោបាយ សង្គ្រាម ច្បាប់ ជាដើម។ យើងឃើញថាគ្រប់ស្នាដៃអក្សរសិល្ប៍បានបង្កប់នូវបញ្ហាសុខៈសម្រាប់មនុស្ស ព្រោះអក្សរសិល្ប៍ចោទនិងដោះស្រាយពីបញ្ហាមនុស្ស។

ឧទាហរណ៍៖

-**រឿងព្រះវេស្សន្តរ** និយាយពីការធ្វើទានដើម្បីបំពេញបារមី ដើម្បីស្វែងរកសុខៈតាមផ្លូវព្រះពុទ្ធសាសនា។

-**រឿងកុលាបប៉ៃលិន** តួអង្គចៅចិត្រខិតខំតស៊ូក្នុងជីវិត ដើម្បីស្វែងរកសុខៈសម្រាប់ខ្លួនឯង។

-**រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់** បានបង្ហាញពីនយោបាយគ្រប់គ្រងនិងអភិវឌ្ឍសង្គម សំដៅស្វែងរកសុខៈ សម្រាប់មនុស្សនៅក្នុងសង្គម។

# មុខងារអក្សរសិល្ប៍

- មុខងារសំខាន់ៗរបស់អក្សរសិល្ប៍មានបីគឺ៖

 -មុខងារផ្ដល់ពុទ្ធិ

 -មុខងារអប់រំ

 -មុខងារសិល្បវិជ្ជា ឬសិល្ប៍សោភ័ណ។

## ១. មុខងារផ្ដល់ពុទ្ធិ

អក្សរសិល្ប៍ មានភារកិច្ចផ្ដល់ពុទ្ធិ ឬចំណេះដឹងដល់អ្នកអាន អ្នកស្ដាប់នូវទស្សនៈ បញ្ញត្តិ ចំណេះដឹងស្ដីពីបញ្ហាជីវភាព បញ្ហាធម្មជាតិ មនោគមវិជ្ជា ទស្សនវិជ្ជា សីលធម៌ ដោយឆ្លុះបញ្ចាំងនូវក្រិត្យក្រមចាំបាច់ក្នុងជីវភាពរស់នៅជាក់ស្ដែង និងជាសំណួមពរដ៏សំខាន់នៃស្នាដៃអក្សរសិល្ប៍។តាមរយៈស្នាដៃអក្សរសិល្ប៍ យើងអាចទាញបាននូវមេរៀនជីវិតផ្សេងៗសម្រាប់ការកែលម្អការរស់នៅរបស់យើង និងអាចជួយរួមវិភាគទានផ្ដល់ចំណេះដឹង ទស្សនៈក្នុងការកែលម្អនូវទម្រង់សង្គម។

## ២. មុខងារអប់រំ

**ស្នាដៃអក្សរសិល្ប៍** គឺជារូបតំណាងឱ្យឧត្ដមគតិក្នុងការបញ្ចុះបញ្ចូលអ្នកអាន អ្នកស្ដាប់ ឱ្យចេះកែប្រែខ្លួនទៅជាមនុស្សល្អក្នុងសង្គម។ លើសពីនេះក៏អាចជួយអ្នកអាន អ្នកស្ដាប់អាចយល់ឃើញនូវទស្សនៈត្រឹមត្រូវប្រកបដោយគតិ បណ្ឌិត គុណធម៌ សីលធម៌ ជាដើម។ ជាពិសេសជួយមនុស្សឱ្យស្រឡាញ់យុត្តិធម៌ គោរពសិទ្ធិមនុស្ស និងបំពេញសកម្មភាពជាកុសល វៀរចាកសកម្មភាពឬអំពើណាដែលជាអំពើអកុសល។

## ៣. មុខងារសោភ័ណ

ស្នាដៃអក្សរសិល្ប៍មិនដូចគ្នានឹងស្នាដៃវិទ្យាសាស្ត្រពិត ឬវិទ្យាសាស្ត្រធម្មជាតិទេ ពីព្រោះអ្នកនិពន្ធ ឬកវីតែងតែប្រើសិល្បវិធីពិសេសប្លែក ដើម្បីបង្កើតសិល្ប៍សោភ័ណសម្រាប់ទាក់ទាញអន្ទងចិត្ត និងមនោសញ្ចេតនារបស់អ្នកអាន អ្នកស្ដាប់ ឱ្យរំភើប រំជើបរំជួល ពីរោះអណ្ដែតអណ្ដូង ភ័យព្រួយ តក់ស្លុត រីករាយ សុខស្រួលទៅតាមបរិយាកាសនៃរឿង។

រសសោភ័ណក្នុងអក្សរសិល្ប៍អាចកើតឡើងដោយសារអ្នកនិពន្ធ ឬកវីចេះបំប្លែងរឿងពិតជាក់ស្ដែងទៅជារឿងអស្ចារ្យ និងបំប្លែងរឿងអស្ចារ្យទៅជារឿងតថភាពវិញ។

# តួអង្គក្នុងអក្សរសិល្ប៍

**តួអង្គ** គឺជាតួដែលមានវត្តមាននិងសកម្មភាពនៅក្នុងរឿងឬដំណើររឿង។

- **តួអង្គក្នុងអក្សរសិល្ប៍មានដូចជា៖**

-តួអង្គសំខាន់

-តួអង្គបន្ទាប់បន្សំ

-តួអង្គវិជ្ជមាន

-តួអង្គអវិជ្ជមាន

-តួអង្គថេរ

-តួអង្គអថេរ

-តួអង្គរំញុក ជាដើម។

១. **តួអង្គសំខាន់** គឺជាតួអង្គដែលមិនអាចខ្វះបាន គឺជាតួអង្គដែលមានវត្តមានតាំងពីដើមរឿងរហូតដល់បញ្ចប់រឿង។

- **តួអង្គសំខាន់ ចែកចេញជាពីរគឺ តួអង្គឯកនិងតួអង្គរង។**

**-តួអង្គឯក** សំដៅលើតួអង្គដែលមានសកម្មភាពច្រើនជាងគេប្រឈមនឹងបញ្ហាស្មុគស្មាញក្នុងដំណើររឿង។

**+តួអង្គឯកតំណាងឱ្យទស្សនៈពីរគឺ៖**

**-តួអង្គឯកតំណាងឱ្យទស្សនៈល្អ ឬគុណសម្បត្តិ៖** ឧទាហរណ៍ ព្រះគោ ក្នុងរឿងព្រះគោព្រះកែវ ជាតួអង្គតំណាងឱ្យគំនិតទស្សនៈរបស់អ្នកនិពន្ធ ដែលមានបំណងជួយការពារប្រទេសខ្មែរពីសៀមឈ្លានពាន។

**-តួអង្គឯកតំណាងឱ្យទស្សនៈអាក្រក់ ឬគុណវិបត្តិ៖** ដូចករណី នាងកាកី ក្នុងរឿងកាកី ជាតួអង្គមានចិត្តមិនស្មោះ ក្បត់ចិត្តស្វាមី។

**-តួអង្គរង** គឺជាតួអង្គដែលធ្វើសកម្មភាពដោយអន្លើៗ ហើយសកម្មភាពទាំងនោះជួយបំពេញដំណើររឿងនិងលក្ខណៈសម្បត្តិឱ្យតួអង្គឯក។ ឧទាហរណ៍ ក្នុងរឿងទុំទាវ នេនពេជ្រ នោ ម៉ឺនងួន ម្ដាយទាវ អរជូន ជាដើមគឺជាតួអង្គរង។តួអង្គទាំងនេះមានសកម្មភាពរួមចំណែកក្នុងបញ្ហារបស់តួអង្គទុំនិងទាវ។

២. **តួអង្គបន្ទាប់បន្សំ** គឺជាតួអង្គក្រៅពីតួអង្គឯក និងតួអង្គរង ដែលមានវត្តមានក្នុងដំណើររឿងតែក្នុងមួយខណៈតែប៉ុ ណ្ណោះ។ តួអង្គបន្ទាប់បន្សំមានវត្តមានម្ដងម្កាលនៅក្នុងរឿងឬដំណើររឿងមានសកម្មភាពជួយបំពេញសាច់រឿងឱ្យកាន់តែវែង។

**ឧទាហរណ៍** ក្នុងរឿងទុំទាវ អ្នកភូមិនៅក្បែងឃ្មុំ ជាតួអង្គបន្ទាប់បន្សំ។

៣. **តួអង្គវិជ្ជមាន** ជាតួអង្គដែលតំណាងឱ្យគុណធម៌ធ្វើសកម្មភាពប្រកបដោយឧត្តមគតិមានចរិតល្អ ស្លូតបូត ជួយយកអាសារគេ ស្រឡាញ់គេ យុត្តិធម៌ ស្រឡាញ់ជាតិមាតុភូមិ ហ៊ានពលីកម្ម និងធ្វើអ្វីៗ ដើម្បីប្រយោជន៍រួមពោលគឺដើម្បីប្រទេសជាតិទាំងមូល។ ឧទាហរណ៍ ក្នុងរឿងរាមកេរ្តិ៍ តួអង្គពាលី ជាតួអង្គដែលហ៊ានពលីកម្មប្តូរជីវិត មិនក្បត់ទឹកដី។ រីឯក្នុងរឿងភូមិតិរច្ឆាន តួអង្គជួននិងនៅ ជាតួអង្គដែលហ៊ានប្តូរជីវិត ដើម្បីសេរីភាពនិងការពារផលប្រយោជន៍ជាតិ។

**៤.តួអង្គអវិជ្ជមាន** គឺជាតួអង្គតំណាងឱ្យអំពើអាក្រក់ គ្មានឧត្តមគតិ មានចរិតកាចសាហាវ គិតតែប្រយោជន៍ផ្ទាល់ខ្លួន រកតែសេចក្តីសុខដាក់ខ្លួន ជាតួអង្គទន់ខ្សោយ គេចយករួចខ្លួន គេចពីការតស៊ូ អស់សង្ឃឹម ជាដើម។

ឧទាហរណ៍៖

**-រឿងភូមិតិរច្ឆាន** តួអង្គបារដេស ជាតួអង្គអាក្រក់ គ្មានឧត្តមគតិ មានចរិតឃោរឃៅ គ្មានចិត្តត្រាប្រណី។

**-រឿងកុលាបប៉ៃលិន** តួអង្គបាឡាត់ស្រុក ជាតួអង្គអាក្រក់ គ្មានឧត្តមគតិ គិតតែពីប្រយោជន៍ផ្ទាល់ខ្លួន។

**-រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់** តួអង្គអ្នកតំណាងរាស្ត្រ ជាមនុស្សបោកប្រាស់។

**៥. តួអង្គថេរ** គឺជាតួអង្គដែលមានចរិតលក្ខណៈមិនផ្លាស់ ប្តូរតាំងពីដើមរឿងរហូតដល់បញ្ចប់រឿង។ ឧទាហរណ៍ តួអង្គចៅចិត្រ ក្នុងរឿងកុលាបប៉ៃលិន ជាតួអង្គមានចរិតលក្ខណៈល្អប្រសើរ មានការតស៊ូក្នុងជីវិត ជឿជាក់លើសមត្ថភាពខ្លួនឯង តាំងពីដើមរឿងរហូតដល់បញ្ចប់រឿង។

**៦. តួអង្គអថេរ** គឺជាតួអង្គដែលផ្លាស់ប្តូរចរិតលក្ខណៈនៅក្នុងវគ្គណាមួយក្នុងផ្ទៃរឿង។ ឧទាហរណ៍ តួអង្គពូហំ ក្នុងរឿងថៅកែចិត្តចោរ បានផ្លាស់ប្តូរគំនិតពីអាក្រក់មកល្អ សុខចិត្តជាប់គុកដើម្បីលាតត្រដាងអំពើអាក្រក់របស់ថៅកែ។

**៧. តួអង្គរំឭក** គឺជាតួអង្គដែលអ្នកនិពន្ធលើកមកនិយាយ ប៉ុន្តែមិនមានវត្តមាននៅក្នុងរឿងទេ គឺអ្នកនិពន្ធគ្រាន់តែរំឭកដល់តែប៉ុណ្ណោះ។ ឧទាហរណ៍ ក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ តួអង្គសម្តេចឪ ជាតួអង្គរំឭក ព្រោះតួអង្គនេះពុំមានវត្តមាន ឬសកម្មភាពនៅក្នុងរឿងទេ អ្នកនិពន្ធគ្រាន់តែលើកយកព្រះនាម និងគោលនយោបាយរបស់ព្រះអង្គមកបង្ហាញតែប៉ុណ្ណោះ។

- **តួអង្គមានចរិតលក្ខណៈដូចជា៖**

**+លក្ខណៈបុគ្គល៖** ជាចំណុចដោយឡែកដែលប្លែកឥតមាននៅក្នុងរឿងដទៃ ហើយត្រូវបានច្នៃប្រឌិតឡើងដោយទស្សនៈផ្ទាល់ខ្លួនរបស់អ្នកនិពន្ធ។

**ឧទាហរណ៍**

**-តួអង្គសត្វក្រពើ** តំណាងឱ្យមនុស្សរមិលគុណ យកទោសតប   គុណ។ យើងឥតឃើញមានស្នាដៃអក្សរសិល្ប៍ដទៃទៀត ដែលរៀបរាប់ពីលក្ខណៈរបស់តួអង្គសត្វក្រពើ ដូចទាំងស្រុងនឹងតួអង្គសត្វក្រពើក្នុងរឿងក្រពើនិងអ្នកបរទេះនេះឡើយ។

**-តួអង្គសុភាសិត** តំណាងឱ្យចៅក្រមដែលប្រកាន់យុត្តិធម៌ មានសមត្ថភាពកាត់ក្តីបានត្រឹមត្រូវ។ លក្ខណៈពិសេសរបស់សុភាទន្សាយក្នុងរឿងនេះខុសពីទន្សាយក្នុងរឿងដទៃ។

**+លក្ខណៈរួម៖** គឺជាទម្រង់ពិសេសនៃអក្សរសិល្ប៍ក្នុងដំណើរការ ផ្តល់ពុទ្ធិនិងឆ្លុះបញ្ចាំងតថភាពដែលគេអាចហៅថា«លក្ខណៈសម័យកាល»។

**ឧទាហរណ៍**

**-តួអង្គ សមនិងសយ** ក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ តំណាងឱ្យកសិករខ្មែរក្នុងសម័យសង្គមរាស្ត្រនិយម។

**-តួអង្គ យាយនួន** ក្នុងរឿងផ្កាស្រពោន តំណាងឱ្យម្តាយខ្មែរ ដែលនិយមប្រើអំណាចទៅលើកូនចៅ ក្នុងការជ្រើសរើសគូស្រករ។

**-តួអង្គ មេឃុំ** ក្នុងរឿងភូមិតិរច្ឆាន តំណាងឱ្យមន្ត្រីរាជការខ្មែរមួយចំនួន ដែលជាអាយ៉ងរបស់បារាំង ពុករលួយ យកចិត្តបរទេស ដើម្បីបានបុណ្យសក្តិនិងទ្រព្យសម្បត្តិ។

**-តួអង្គ ទុំនិងពេជ្រ** ក្នុងរឿងទុំទាវ តំណាងឱ្យព្រះសង្ឃខ្មែរ ដែលបានរៀនសូត្រអំពីសាសនា វប្បធម៌ និងវិជ្ជាជីវៈក្នុងវត្តអារាម នៅសម័យលង្វែក។

**-តួអង្គ ម្តាយទាវ** ក្នុងរឿងទុំទាវ តំណាងឱ្យមាតាខ្មែរសម័យលង្វែក ដែលប្រកាន់យកទស្សនៈនំមិនធំជាងនាឡិ។

- **ការវិភាគតួអង្គ** ជាការសិក្សាវិភាគឱ្យបានស៊ីជម្រៅនិងឱ្យឃើញពីលក្ខណៈសម្បត្តិពីរយ៉ាង គឺគុណសម្បត្តិនិងគុណវិបត្តិតាមរយៈ អាកប្បកិរិយា ចរិតលក្ខណៈ សកម្មភាព កាយវិការ ចិត្តគំនិត សម្លៀកបំពាក់របស់តួអង្គ។
- **វិធីបង្ហាញតួអង្គ** គឺជាការប្រាប់ពីឈ្មោះ អាយុ ឋានៈ ប្រភពកំណើតរបស់តួអង្គនីមួយៗនៅក្នុងរឿង ដើម្បីឱ្យអ្នកអានបានស្គាល់។
- **វិធីបង្ហាញតួអង្គក្នុងអក្សរសិល្ប៍មាន៤យ៉ាងគឺ៖**

  -ការបង្ហាញតាមរយៈអ្នកនិពន្ធ

  -ការបង្ហាញតាមរយៈតួអង្គខ្លួនឯង

  -ការបង្ហាញតាមរយៈតួអង្គផ្សេងៗទៀត

  -ការបង្ហាញតួអង្គតាមរយៈដំណើររឿង។

# វិធីតែងនិពន្ធ

**ការសិក្សាអំពីវិធីតែងនិពន្ធ** ជាការសិក្សាពីរបៀបតាក់តែងរឿង ដែលមានច្រើនប្រភេទដូចជា តែងរឿងបុរាណ រឿងទំនើប ហើយរឿងនីមួយៗមានលក្ខណៈពិសេសដោយឡែកៗពីគ្នាតាំងពីចំណុចផ្ដើមរឿង តួរឿង និងបញ្ចប់រឿង។

**១. ការផ្ដើមរឿង**

អ្នកនិពន្ធសរសេរផ្ដើមរឿងតាមវិធីផ្ដើមដោយមានការបង្ហាញ៖

-ធម្មជាតិនៅត្រង់កន្លែងណាមួយ

-ឈ្មោះតួអង្គឬទំនាស់

-សកម្មភាព ជាដើម។

**ឧទាហរណ៍៖** ការផ្ដើមរឿងរបស់អ្នកនិពន្ធ នូ ហាច នៅក្នុងរឿងផ្កាស្រពោន៖ រទេះភ្លើងបោលលឿនដូចព្យុះកាត់ព្រៃខ្លុងនិងព្រិច រត់ឆ្លងអូរ ហើយជ្រែកពុះជើងភ្នំដោយបញ្ចេញសន្ធឹកខ្ទរំពងធ្វើឱ្យរញ្ជួយផែនពសុធា។(...)

**២. តួរឿង**

នៅក្នុងតួរឿង អ្នកនិពន្ធបានប្រើវិធីច្រើនយ៉ាង ដើម្បីធ្វើឱ្យដំណើររឿងស្របគ្នាទៅនឹងបញ្ហាចោទ និងដំណោះស្រាយក្នុងរឿង ដោយធ្វើយ៉ាងណាឱ្យសាច់រឿងមានសកម្មភាពប្រទាក់ក្រឡាគ្នា ហើយមានភាពរស់រវើកធ្វើឱ្យអ្នកអាន អ្នកស្ដាប់ និងអ្នកទស្សនាជក់ចិត្តជិតអារម្មណ៍...។

-**ពណ៌នាវិធី៖** គឺអ្នកនិពន្ធប្រើវិធីរៀបរាប់ធម្មជាតិ តួអង្គ សកម្មភាពប្រកបដោយសិល្បៃរូបារម្មណ៍ខ្ពស់ ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ ហាក់ដូចជាឃើញរូបពិតក្នុងអារម្មណ៍របស់ខ្លួន។

-**សំវាទវិធី៖** គឺអ្នកនិពន្ធប្រើវិធីរៀបរាប់បង្កើតនូវស្ថានភាពផ្សេងៗនៅក្នុងសាច់រឿងដើម្បីឱ្យតួអង្គសន្ទនាគ្នាឬនិយាយឆ្លើយឆ្លងគ្នាទៅវិញទៅមក។

-**ឯកវាទវិធី៖** គឺវិធីដែលអ្នកនិពន្ធធ្វើឱ្យតួអង្គនិយាយតែម្នាក់ឯងឬគិតទៅលើបញ្ហាអ្វីមួយក្នុងជីវិតក្នុងសាច់រឿងរបស់ខ្លួន ទោះជាការគិតនោះមានស្ថានភាពបែបណាក៏ដោយ។

-**ឧបមានវិធី៖** ជាវិធីដែលអ្នកនិពន្ធលើកយកនូវការប្រៀបប្រដូចអ្វីមួយទៅនឹងអ្វីមួយទៀត ដោយប្រើសិល្បៈវិធីនិងសិល្បៃរូបារម្មណ៍។

-**ហាសវិធី៖** អ្នកនិពន្ធប្រើវិធីធ្វើឱ្យអ្នកអាន អ្នកស្ដាប់ផ្ទុះសំណើចសប្បាយរីករាយតាមដំណើររឿង។

-**បដិវិធី៖** អ្នកនិពន្ធប្រើវិធីបង្ហាញនូវភាពខុសគ្នា ផ្ទុយគ្នាពីស្ថានភាព សកម្មភាព តួអង្គ ឬព្រឹត្តិការណ៍ណាមួយ ដើម្បីរំលេចផ្ទៃរឿងតាមមនោគតិរបស់ខ្លួន។

-**សន្ទេហវិធី៖** ជាវិធីដែលអ្នកនិពន្ធបង្កើតឡើងនៅក្នុងដំណើររឿងរបស់ខ្លួន ដើម្បីឱ្យអ្នកអាន អ្នកស្តាប់ឆ្ងល់ចង់ដឹងតទៅទៀត។

-**វឌ្ឍមានវិធី៖** វិធីតែងនិពន្ធមួយបែបដែលកវី អ្នកនិពន្ធធ្វើឱ្យដំណើររឿងមានការរីកចម្រើនពីធូរស្រាលទៅតានតឹង ឬពីតានតឹងទៅធូរស្រាលវិញ។

-**វចនវិធី៖** អ្នកនិពន្ធចេះប្រើពាក្យពេចន៍សាមញ្ញ ងាយអាន ងាយស្តាប់ ងាយយល់ ឬប្រើពាក្យពេចន៍ពិបាកយល់ ពិបាកអានដូចជាពាក្យខ្មែរបុរាណ បាលី-សំស្រ្កឹត...។

-**រចនាវិធី៖** ជាវិធីដែលអ្នកនិពន្ធប្រើដើម្បីសរសេរតាក់តែងអត្ថបទរឿងរបស់ខ្លួន ទោះជាពាក្យរាយ ពាក្យកាព្យឱ្យមានពាក្យពេចន៍ ឃ្លា ល្បះធម្មតាៗដែលប្រជាជនទូទៅនិយមប្រើ ធ្លាប់ស្តាល់ ធ្លាប់ប្រើ មិនពិបាកអាន ពិបាកស្តាប់ ឬពិបាកយល់ឡើយ។

**៣.ការបញ្ចប់រឿង៖** ជាវិធីដែលអ្នកនិពន្ធសរសេរបញ្ចប់រឿងរបស់ខ្លួនដោយវិធីច្រើនយ៉ាង។ជួនកាលអ្នកនិពន្ធសរសេរបញ្ចប់រឿងដោយ៖

-ឱ្យតួអង្គឯករបស់រឿងនៅរស់

-ជួនកាលឱ្យតួអង្គឯកស្លាប់

-ជួនកាលបញ្ចប់រឿងទាំងមូលដោយក្តីសង្ឃឹមគ្រប់គ្នា

-ជួនកាលបញ្ចប់រឿងទាំងមូលដោយបន្សល់ក្តីអស់សង្ឃឹមឬបរាជ័យទៅតាមឧត្តមគតិរបស់អ្នកនិពន្ធ

-ជួនកាលអ្នកនិពន្ធទុកឱ្យអ្នកអានគិតពិចារណាបញ្ចប់ដោយខ្លួនឯង ជាដើម។

- **ហេតុអ្វីបានជាអ្នកនិពន្ធបង្កើតស្នាដៃអក្សរសិល្ប៍ខ្មែរ?**

**-ដើម្បីខ្លួនឯង**

អ្នកនិពន្ធមានបំណងរំដោះខ្លួនពីការឈឺចាប់ និងភាពទុក្ខព្រួយរបស់គាត់ ពោលគឺតាមរយៈស្នាដៃអក្សរសិល្ប៍ ជាមធ្យោបាយមួយដែលគេបានរកឃើញនូវខ្យល់ដកដង្ហើមបានស្រួល មិនសូវមានការលំបាកខាងផ្លូវចិត្ត នៅក្នុងពិភពលោកនិងមានការសប្បាយច្រើនចំពោះខ្លួនឯង។

**-ដើម្បីមនុស្សទាំងពួង**

អ្នកនិពន្ធបានសរសេរស្នាដៃរបស់ខ្លួនដើម្បី៖

- ទាក់ទាញមនុស្សទាំងឡាយ ការចែករំលែកនូវការឈឺចាប់របស់ខ្លួន។ គេតែងតែនិយាយថាស្នាដៃមួយជានិច្ចកាល ជាសម្រែកនៅក្នុងទីហោស្ថាន ជាការលែងព្រាបដោយចងសារមួយភ្ជាប់នឹងជើងរបស់វា។
- ចោទសួរដល់មនុស្សទាំងឡាយនូវបញ្ហា ឬមតិយោបល់ផ្សេងៗក្នុងន័យបំភ្លឺនូវភាពងងឹត ស្រអាប់ដែលពិបាកយល់។

- បង្កើតពិភពប្លែកៗឆ្ពោះទៅរកគោលដៅតថៈ តែមិនមែនជាការផ្លុះបញ្ចាំងតថៈឡើងវិញដោយឥតខ្វោះឡើយ។

**ការសិក្សាអត្ថបទ**

## ១. គម្រោងទូទៅនៃការសិក្សាអត្ថបទ

### ១.១.ការបង្ហាញអត្ថបទ

#### ១.១.១. អត្ថបទ

- ចំណងជើង
- ប្រភព
- ប្រភេទ (រឿងនិទាន បុរាណ ទំនើប ល្ខោន...)
- ចលនា(ព្រាហ្មណ៍និយម ពុទ្ធនិយម ខេមរនិយម បរទេសនិយម)។

#### ១.១.២. អ្នកនិពន្ធ

- ឈ្មោះអ្នកនិពន្ធ
- ជីវប្រវត្តិ
- ស្នាដៃសំខាន់ៗ។

#### ១.១.៣. កាលកំណត់តែង

- ថ្ងៃខែឆ្នាំ នៃការតាក់តែង
- ថ្ងៃខែឆ្នាំ នៃការបោះពុម្ព។

#### ១.១.៤. សង្គមបរិយាកាស

- កាលប្រវត្តិ(សម័យកាលកកើតឡើង)
- ព្រឹត្តិការណ៍សំខាន់ៗ។

### ១.២. ការវិភាគអត្ថបទ

#### ១.២.១. ស្ថានភាពរឿង

- សង្ខេបរឿង
- តួអង្គ(តួអង្គឯក តួអង្គរង តួអង្គបន្ទាប់បន្សំ តួរំពូក)
- កាលអាកាស
- ព្រឹត្តិការណ៍សំខាន់ៗឬបញ្ហាសង្គមដែលបង្ហាញក្នុងរឿង។

#### ១.២.២. អត្ថន័យ

- ប្រធានរឿង
- មូលបញ្ហារឿង
- ទំនាស់
- វិភាគតួអង្គ (គុណសម្បត្តិ គុណវិបត្តិ)
- ឧត្តមគតិរឿង។

**១.២.៣. អត្ថរូប**

- វិធីតែងនិពន្ធ (ពាក្យរាយ ពាក្យកាព្យ កម្រងកែវ ល្ខោន និងការប្រើប្រាស់ភាសា...)
- ការផ្ដើមរឿង (ការបង្ហាញតួអង្គ រៀបរាប់ទេសភាព នមស្ការព្រះរតនត្រៃ ហោមពិធី...)
- ដំណើររឿង (ពណ៌នាដំណើររឿងដោយនិទានវិធី សំវាទវិធី ឯកវាទវិធី សន្ទេហវិធី...)
- ការបញ្ចប់រឿង (សង្ឃឹមគឺ ជួបជុំទទួលជោគជ័យ អស់សង្ឃឹមគឺ បែកបាក់ព្រាត់ប្រាស...)។

**១.២.៤. អត្ថរស**

- កុសលរស
- សង្គមរស
- តថរស
- វីររស
- អច្ឆរិយរស
- ហាសរស
- ទារុណរស....។

**១.២.៥. បញ្ហាសង្គម**

**ក. នយោបាយ**

- ក្នុងប្រទេស (អ្នកគ្រប់គ្រង របបគ្រប់គ្រង...)
- ក្រៅប្រទេស (ទំនាក់ទំនងខាងក្រៅ ឬទំនាក់ទំនងអន្តរជាតិ...)។

**ខ. សេដ្ឋកិច្ច**

- កសិកម្ម
- ផលិតកម្ម សិប្បកម្ម
- ឧស្សាហកម្ម
- ពាណិជ្ជកម្ម
- គមនាគមន៍
- ទេសចរណ៍។

គ. សង្គមកិច្ច

- ស្ថានភាពរស់នៅ
- មុខរបរនិងជីវភាពរបស់ប្រជាជន
- សុខាភិបាល...។

ឃ. វប្បធម៌

- ជំនឿ ប្រពៃណី ទំនៀមទម្លាប់
- សាសនា
- ការសិក្សាអប់រំ
- សិល្បៈ....។

១.៣. ការសន្និដ្ឋាន

# កាព្យរូបារម្មណ៍

## ១. និយមន័យ

**កាព្យរូបារម្មណ៍** គឺជារូបារម្មណ៍ដែលមាននៅក្នុងអត្ថបទកាព្យឬកំណាព្យ។

## ២. ប្រភេទនៃកាព្យរូបារម្មណ៍

### ក. បំរៀបន័យរូបារម្មណ៍

**បំរៀបន័យរូបារម្មណ៍** គឺជារូបារម្មណ៍ដែលកើតឡើងតាមរយៈការធ្វើឱ្យវត្ថុមួយឥតមានជីវិត ឥតចេតនា ឥតវិញ្ញាណឱ្យប្រែក្លាយជាមានជីវិត មានវិញ្ញាណឡើង តាមរយៈការប្រៀបធៀបវត្ថុពីរដោយមិនប្រើពាក្យប្រៀបធៀប។

ឧទាហរណ៍៖ ភ្នំភ្លើង ស្ទឹងឈាម សមុទ្រមេឃា នារាតណ្ហា អន្លង់ស្នេហ៍ ជើងភ្នំ ជាដើម។

### ខ. រូបារូប្បារម្មណ៍

**រូបារូប្បារម្មណ៍** គឺជារូបារម្មណ៍បង្កើតឡើងដោយកវីចេះប្រើពាក្យពេចន៍ទាក់ទងនឹងការបង្ហាញពីប្រព័ន្ធនៃជីវរូបារម្មណ៍ដូចជា៖

-**ចក្ខុរូបារម្មណ៍** ជារូបារម្មណ៍ដែលកើតឡើងដោយសារកវីប្រើពាក្យពេចន៍ទាក់ទាញហាក់ឃើញផ្ទាល់នឹងភ្នែក។

**ឧទាហរណ៍៖**

មាត់នាងញញឹម ភក្ត្រនាងសង្ឃឹម សម្តីស្មោះស
ហត្ថទាំងគូ គន់យូររឹតល្អ ម្រាមថ្លោសបវរ
សការងារល្បី។

-**សោតរូបារម្មណ៍** ជារូបារម្មណ៍ដែលកើតឡើងដោយសារកវីប្រើពាក្យពេចន៍ទាក់ទងនឹងការបង្ហាញសូរសំឡេងរណ្តំស្រះ រណ្តំព្យញ្ជនៈ ទាក់ទងនឹងសូរសំឡេងធម្មជាតិ ដែលធ្វើឱ្យយើងស្តាប់ឮមានចិត្តរំភើប។

ឧទាហរណ៍៖

ភ្លៀងធ្លាក់ស្រិបៗមិនឈប់ឈរ ភ្លៀងហូរតាមទសូរតក់ៗ
កង្កែបកបៗតាមដើមកក់ ខ្យល់បក់ហ៊ូៗតាមបង្អួច។

-**ឃានជីវ្ហារូបារម្មណ៍** ជារូបារម្មណ៍ដែលកើតឡើងដោយការប៉ះទង្គិចរវាងក្លិនក្រអូប ស្អុយ ឆ្អេះឆ្អាប រសផ្អែម ជូរចត់...ទៅនឹងឃាន(ការដឹងដោយច្រមុះ) និងជីវ្ហា(ការដឹងដោយអណ្តាត)។

**ឧទាហរណ៍៖**

នឹកដល់ពេលយប់ ដូចផ្កាយីហ៊ុប ពិដោរនួនល្អង

ក្រអូបជាប់ជិត ឈ្ងុយឈ្ងប់ជាប់ចង ក្លិនជាចំណង

ចងគុកតណ្ហា។[...] **(ចិត្តក្រមុំ កេង វ៉ាន់សាក់)**

ធុំហើយក្លិនគុក ឆ្អេះឆ្អាបគ្រប់មុខ តែធ្លាប់ធុំឆ្ងាញ់

ពិដោរកន្និដ្ឋា ស្រវាខ្នួលខ្ញាញ់ នឹកឡើងគ្នាន់ក្នាញ់

ធុំចង់ថើបធួន។ **(គុកកាមកិលេស កេង វ៉ាន់សាក់)**

-**កាយរូបារម្មណ៍** ជារូបារម្មណ៍ដែលកើតឡើងដោយសារកវីប្រើពាក្យ ឃ្លា ល្បះ ដើម្បីបង្កើតការរំភើបតាមរយៈកាយិន្ទ្រិយ។

ឧទាហរណ៍៖

បងចាំកេសីបីខ្មៅញាប់ ប្អូនក្រសោបចាប់ចងចារផ្កា

កែមក្បួតម្រួតមាលា អស់ផ្កាសារពើភ្ញី។ **(រាមកេរ្តិ៍ ខ្សែទី៤)**

## គ. ឧបមានរូបារម្មណ៍

**ឧបមានរូបារម្មណ៍** ជារូបារម្មណ៍ដែលកើតឡើងពីការប្រៀបធៀបអង្គបង្គោលនិងទំហៀបពីរឬច្រើនដោយប្រើចំណងធៀប។ ចំណងធៀបមានដូចជា ដូច ប្រៀបដូច ហាក់ដូចជា ដូចជា ប្រៀបបាន ច្រឡំនឹង ប្រហែលជា យ៉ាងណា មិនបាន មិនខុសពី...។

ឧទាហរណ៍៖

ទុំថាខ្លួនបងដូចរាជសីហ៍ ខ្លួននាងទាវស្រីដូចគុហា

រាជសីហ៍បើបានលំនៅជា មិនឱ្យឃ្លាតឃ្លាគុហាឡើយ។ **(ទុំទាវ ភិក្ខុសោម)**

# ការវិវត្តនៃអក្សរសិល្ប៍ខ្មែរ

គេចាត់ទុកអក្សរសិល្ប៍ជាកញ្ចក់មួយប្រភេទយ៉ាងសំខាន់របស់សង្គមមនុស្ស។ តាមរយៈអក្សរសិល្ប៍ គេអាចឆ្លុះមើលការរស់នៅដ៏ជាក់ស្ដែងរបស់មនុស្សក្នុងសម័យកាលនីមួយៗព្រោះអក្សរសិល្ប៍តែងតែប្រែប្រួលទៅតាមដំណើរវិវត្តរបស់សង្គមមនុស្សជាដរាប។

**១. អក្សរសិល្ប៍សម័យបុរាណ**

**ក. មុនសម័យអង្គរ (ស.វទី១ ដល់ទី៨)**

នៅសម័យមុនអង្គរ គេនិយមប្រើភាសាសំស្ក្រឹតដែលគេចាត់ទុកជាភាសាជាន់ខ្ពស់(ភាសាអ្នកប្រាជ្ញ)។ ដូចនេះហើយបានជាមានសិលាចារឹកខ្លះសរសេរជាភាសាសំស្ក្រឹត ហើយតែងជាពាក្យកាព្យ។

-សិលាចារឹកជាភាសាសំស្ក្រឹតដែលចំណាស់ជាងគេគឺសិលាចារឹកវ៉ូកាញ់(ប្រមាណគ.សទី២-៣)។ អត្ថបទនៃសិលាចារឹកនេះនិយាយពីសន្ដានចិត្តរបស់ព្រះរាជាមួយអង្គដែលគិតដល់សុភមង្គលរបស់ប្រជារាស្ត្រ ដោយព្រះអង្គធ្វើជាបទបញ្ញាទុកឱ្យមហាក្សត្រតៗមកប្រតិបត្តិតាម។

-សិលាចារឹកខ្លះសរសេរជាភាសាខ្មែរបុរាណ ហើយជាពាក្យកាព្យ ចាប់តាំងពីស.វទី៧។

-សិលាចារឹកដែលចាស់ជាងគេ គឺសិលាចារឹកអង្គរបុរី(គ.ស៦១១)

ដូច្នេះសិលាចារឹកនៅសម័យមុនអង្គរ ច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រនិងសាសនា។

**ខ. សម័យអង្គរ (៨០២ដល់១៤៣១)**

អក្សរសិល្ប៍សម័យអង្គរ ពិតមែនតែបានទទួលបន្តបន្ទាប់គ្នានូវឥទ្ធិពលនៃលទ្ធិព្រាហ្មណ៍សាសនា និងពុទ្ធសាសនា ប៉ុន្តែបានរក្សាជាលក្ខណៈខ្មែរ។ ដោយយកតួអក្សរខ្មែរពិតប្រាកដមកធ្វើជាឧបករណ៍ អក្សរសិល្ប៍ខ្មែរសម័យនោះបានផ្ដិតជាប់ទៅនឹងសម្ភារៈពីរបែប ទីមួយគឺអក្សរសិល្ប៍ដែលសរសេរដោយដីសបំពង់នៅលើស្បែកសត្វស្ងួត លាបពណ៌ខ្មៅ។ ទីពីរ គឺអក្សរសិល្ប៍ដែលចារនៅលើផ្ទាំងថ្មជាបន្ទះ ឬជាបង្គោល ឬជាសសរ។

ក្នុងការសរសេរអត្ថបទអក្សរសិល្ប៍អ្នកនិពន្ធប្រើភាសាពីរគឺភាសាសំស្ក្រឹត និងភាសាខ្មែរបុរាណ។

-**អត្ថបទជាភាសាសំស្ក្រឹត** ច្រើនជាពាក្យកាព្យ ដែលនិយាយអំពីកំណត់ហេតុក្នុងដំណើរប្រព្រឹត្តទៅនៃប្រវត្តិរបស់ព្រះរាជាឬមន្ត្រី ឬជាការអួតសរសើរចំពោះតួអង្គណាមួយក្នុងប្រវត្តិសាស្ត្រ។

-**អត្ថបទជាភាសាខ្មែរ** ច្រើនជាពាក្យឧទ្ទិស ឬជាបញ្ជីរាប់រេហ៍ពល រាប់វត្ថុដែលគេបូជាសម្រាប់បូជនីយដ្ឋានទាំងឡាយ។

នៅសម័យអង្គរតាមរយៈអត្ថបទសិលាចារឹកគេប្រទះឃើញឈ្មោះអ្នកនិពន្ធ៖

-**បណ្ឌិតសោម៖** សិលាចារឹកប្រាសាទកណ្ដាលដើមរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័ន។

-**បណ្ឌិតយតិអមរភាវៈ** ៖ សិលាចារឹកប្រាសាទភ្នំប៉ាយង់រជួកាលព្រះបាទសោយវរ្ម័ន។

-នៅមានបណ្ឌិតជាច្រើនទៀត ដូចជា **បណ្ឌិតទិវាករ បណ្ឌិតកវិន្ទ្រៈ បណ្ឌិតភូបន្ទ្រៈ និងព្រះនាងឥន្ទ្រទេវី**។

## ២. អក្សរសិល្ប៍សម័យកណ្តាល

### ក. សម័យក្រោយអង្គរ (១៤៣១ដល់១៨៦២)

កាលពីសម័យមុនៗអក្សរសិល្ប៍ខ្មែរមានការរីកចម្រើន ស្រាប់ តែមកដល់ពេលនេះអក្សរសិល្ប៍ខ្មែរប្រែជាមានសភាពអាប់អួរ ដោយសារបច្ចាមិត្តមករាតត្បាត បណ្តាលឱ្យមានចម្បាំង ធ្វើឱ្យមានភាពដុនដាបខាងសេដ្ឋកិច្ច មានការអត់ឃ្លាន មានជំងឺឆ្លង ហើយមានការទាស់ទែងគ្នាក្នុងស្រុកយ៉ាងច្របូកច្របល់។ ស្ថានភាពបែបនេះនាំឱ្យប្រទេសនិងប្រជារាស្រ្តខ្មែរទន់ខ្សោយ។ លុះមកដល់សតវត្សទី១៧ ស្នាដៃអក្សរសិល្ប៍ខ្មែរក៏ចាប់ផ្តើមងើបឡើងវិញ សម្ភារៈដែលគេកត់ត្រាអក្សរសិល្ប៍ពេលនោះគឺក្រាំង (ស្លឹកក្រជាសស្មាច់ក្រាស់បត់ជាផ្នត់) និងស្លឹករឹត(សាស្ត្រា)។ ប៉ុន្តែជាអកុសលកេរដំណែលក្រាំងនិងសាស្ត្រាស្លឹករឹតចេះតែវិនាសទៅ ដោយសារសង្គ្រាម និងការឈ្លានពានរបស់ខ្មាំងបរទេសដែលបានប្រមូលយកទៅ ឬដុតបំផ្លាញចោល។

នៅពេលនោះដែរ គេសង្កេតឃើញស្នាដៃអក្សរសិល្ប៍សាមញ្ញជាច្រើនបានកើតឡើងដូចជា រឿងព្រេង រឿងនិទានខ្លីៗ ដែលនាំឱ្យអ្នកស្រុកស្តាប់និងយល់បានដោយស្រួល។

+ឈ្មោះអ្នកនិពន្ធនិងស្នាដៃនៅសម័យកណ្តាលគឺ៖

-**អ្នកប៉ាង** ៖ និពន្ធស្នាដៃ«ល្បើកអង្គរ គ.ស.១៦០៩។

-**ព្រះរាជសម្ភារៈ** និពន្ធស្នាដៃ «ច្បាប់ព្រះរាជសម្ភារ គ.ស.១៦២២» «ហេមន្តមាស គ.ស.១៦២៩» «ហីនល័ក្ខណ៍ គ.ស.១៦៣០»និង «កាព្យនិរាស គ.ស.១៦៦០»។

-**បណ្ឌិតជ័យនន្ទ** សរសេរស្នាដៃជាភាសាខ្មែរមុនគេ (សិលាចារឹក គ.ស.១៧០១)

-**ឧកញ៉ាកោសាធិបតីកៅ** ៖ និពន្ធរឿងក្រុងសុភមិត្រ គ.ស.១៧៩៨

-**ឧកញ៉ាព្រះឃ្លាំងនង៖** និពន្ធច្បាប់សុភាសិត គ.ស.១៧៩០ លោកនេយ្យជាតក គ.ស.១៧៩៤ បុញ្ញសារសិរសា គ.ស.១៧៩៧ និងភោគកុលកុមារ គ.ស.១៨០៤។

-**ឧកញ៉ាសន្ធរវោហាម៉ុក៖**និពន្ធរឿងទេវន្ទ ល្បើកចចក រឿងទុំទាវ

-**វិសេសជួង៖** ល្បើកជុចនិងត្រី និងល្បើកជូជក

-**ព្រះបាទអង្គឌួង៖** និពន្ធចម្ប៉ាថោង គ.ស.១៨១០ រឿងកាកី គ.ស.១៨១៥ ច្បាប់ស្រី គ.ស.១៨៣៧ និងរឿងព្រះវេស្សន្តរ តែងជាពាក្យរាយ។

## ៣. អក្សរសិល្ប៍សម័យទំនើប

ដំណាក់កាលនេះអក្សរសិល្ប៍មានការវិវត្តខ្លាំងក្លា ដែលយើងអាចចែកជា៥សម័យកាលគឺ **សម័យបារាំង សម័យសង្គមរាស្ត្រ**
**និយម សម័យសាធារណរដ្ឋខ្មែរ សម័យកម្ពុជាប្រជាធិបតេយ្យ សម័យក្រោយថ្ងៃ៧មករា ១៩៧៩-បច្ចុប្បន្ន។**

**១. សម័យអាណាព្យាបាលបារាំង (១៨៦៣ដល់១៩៥៣)**

នៅសម័យអាណាព្យាបាលបារាំង អក្សរសិល្ប៍ខ្មែរចុះអន់ថយអាប់រស្មីនិងពុំសូវមានការនិយមប្រើអក្សរខ្មែរទេ។ រីឯក្បួនខ្នាតអក្សរខ្មែរឃើញមានតែនៅក្នុងវត្តអារាម មានព្រះសង្ឃជួយថែរក្សាឱ្យគង់វង្ស។

**ក. ស្ថានភាពអក្សរសិល្ប៍ខ្មែរនាសម័យបារាំង**

-ពួកអាណាព្យាបាលបារាំងបានចាប់បង្ខំកូនខ្មែរឱ្យរៀនភាសាបារាំងតាំងពីថ្នាក់ដំបូងឡើងទៅ។

-អក្សរខ្មែរបានទៅជ្រកកោនក្នុងទីវត្តអារាមព្រះពុទ្ធសាសនា ហើយក៏មានកូនចៅខ្មែរមួយចំនួនធំទៅសិក្សារៀនសូត្រដែរ។

-ការតាក់តែងនិពន្ធស្នាដៃគ្រប់យ៉ាងត្រូវឆ្លងកាត់ការត្រួតពិនិត្យរបស់ពួកបារាំង។

-ទោះជាមានគំនាបពីបារាំងក្តី ក៏នៅតែមានការបង្កើតស្នាដៃមួយចំនួនដែលបានបង្កប់ខ្លឹមសាររិះគន់របបគ្រប់គ្រងបែបនេះដែរ ដូចជារឿងកូនចៀមនិងចចក របស់កវីនិពន្ធសុតន្តប្រីជាឥន្ទ ច្បាប់ល្បើកថ្មី របស់លោកតាក្រម ង៉ុយ និងស្នាដៃជាច្រើនទៀត។

-សម័យនេះមានភាពរីកដុះដាលក្នុងការនិពន្ធប្រភេទអក្សរសិល្ប៍ប្រលោមលោក ដែលទទួលឥទ្ធិពលពីបរទេស ដោយសរសេរជាអត្ថបទពាក្យរាយ។

**ខ. រឿងប្រលោមលោកល្បីៗ** ក្នុងសម័យអាណាព្យាបាលបារាំង ហើយកំពុងបញ្ចូលក្នុងកម្មវិធីសិក្សានាពេលបច្ចុប្បន្នគឺះ

-រឿងភូមិតិរច្ឆាន

-រឿងគ្រូបង្រៀនស្រុកស្រែ

-រឿងគូលីកំណៃន

-រឿងផ្កាស្រពោន

-រឿងមាលាដួងចិត្ត ជាដើម។

**គ. អ្នកនិពន្ធល្បីៗនៅសម័យបារាំង**

នៅសម័យបារាំងនេះ គេអាចចែកអ្នកនិពន្ធជាពីរប្រភេទគឺ

**១. អ្នកនិពន្ធបែបប្រពៃណី មុនទទួលឥទ្ធិពលប្រលោមលោកបស្ចិមប្រទេស**

អ្នកនិពន្ធក្នុងប្រភេទនេះ គឺទទួលការសិក្សាបែបតាមប្រពៃណីពីសំណាក់គ្រូបាអាចារ្យ ជាព្រះសង្ឃតាមវត្តអារាមនានា ដែលជាឃ្លាំងផ្ទុកនូវចំណេះដឹងសព្វយ៉ាងទាំងអក្សរសាស្ត្របរ្បធម៌ អរិយធម៌ ទស្សន

វិជ្ជា លេខនព្វន្ត បច្ចេកទេស ហត្ថកម្មផ្សេងៗជាច្រើនរបស់ជាតិ។ ជាទូទៅអ្នកនិពន្ធទាំងនេះ ពុំបានទទួលការសិក្សាតាមបែបទំនើប ឬឥទ្ធិពលប្រលោមលោកផ្សេងៗនៃអក្សរសិល្ប៍បស្ចិមប្រទេសនោះទេ។ ពេលខ្លះអ្នកនិពន្ធ ជាព្រះសង្ឃក៏មាន ហើយអត្ថបទតែងគឺជាអត្ថបទកាព្យ ជាសាស្ត្រាល្បែងតាមបែបសាសនា តាំងពីសម័យមុន រហូតដល់ពាក់កណ្តាលទីមួយនៃសតវត្សទី២០ នៅពេលអ្នកនិពន្ធតាមបែបប្រលោមលោកទំនើបចូលមកជំនួសទើបអស់អត្ថិភាព។ អ្នកនិពន្ធទាំងអស់នោះ ជាអ្នករក្សាទម្រង់និម្មិតកម្មស្នាដៃតាមបែបសាសនា បានយ៉ាងខ្ជាប់ខ្ជួន។

❖ វិធីនិម្មិតកម្មនោះគឺ

- ផ្នែកអត្ថន័យ ៖ និយាយពីការអន្ទោលកើតស្លាប់ក្នុងជាតិផ្សេងៗ ដើម្បីកសាងបារមីរបស់តួអង្គព្រះពោធិសត្វ មានការកសាងបារមីទាំងដប់ក្នុងរឿងទសជាតក ការកសាងបារមីផ្សេងៗក្នុងរឿងពុទ្ធនិយមក្លាយ(រឿងបញ្ញាសជាតក) និងក្នុងរឿងពុទ្ធនិយមក្លាយហួសហេតុ ឬផ្លូម) ក្នុងបំណងត្រាស់ជាព្រះពុទ្ធនាអនាគតជាតិនៅក្នុងគោលពុទ្ធនិយម។ ការបង្ក្រាបសភាវៈអាក្រក់របស់អវតារព្រះវិស្ណុដែលជាតំណាងសភាវៈល្អ នៅក្នុងគោលព្រាហ្មណ៍និយម។
- ផ្នែកអត្ថរូប ៖ ស្នាដៃនិពន្ធឡើងជាពាក្យកាព្យ ពោរពេញទៅដោយពាក្យចួន ផ្ទួន រណ្តំ ណែងណងបន្តគ្នា ប្រកប
  រូបារម្មណ៍នៃសាសនា ដើម្បីបន្ទន់ចិត្តអ្នកអាន អ្នកស្តាប់ ឱ្យជក់ចិត្តជិតអារម្មណ៍ អណ្តែតអណ្តូងទៅក្នុងអច្ឆរិយភាពរបស់សាសនា ដោយប្រើពាក្យពេចន៍ជាភាសាបាលី(មគធភាសា) សំស្រ្កឹតដែលគេយល់ថាជាភាសាប្រសើរខ្ពង់ខ្ពស់ មានក្បួនខ្នាតត្រឹមត្រូវ ជាភាសារបស់អាទិទេពលាយឡំជាមួយភាសាខ្មែរបុរាណ។

❖ អ្នកនិពន្ធនិងស្នាដៃលេចធ្លោមួយចំនួនក្នុងសម័យនោះ៖

- ព្រះធម្មបញ្ញា អ៊ុក និពន្ធរឿងមរណមាតា ១៨៧៧
- ព្រហ្មបវរភក្តី និពន្ធរឿងពោធិវង្ស ១៨៨១
- ឧកញ៉ាវង្សាធិបតីអ៊ុក និពន្ធរឿងសង្ខសិល្ប៍ជ័យ ១៨៨២
- ឃុនសន្ធរពិនិត្យ និពន្ធរឿងចៅមាស ១៨៨៧
- ចៅអធិការវត្តព្រែកប្រណាក និពន្ធរឿងព្រះលក្ខិណវង្ស នៅឆ្នាំ១៨៩០
- ហ្មឺនភក្តីអក្សរតន់ និពន្ធរឿងសព្វសិទ្ធិ (បទពាក្យ៧) នៅឆ្នាំ១៨៩៩
- ឧកញ៉ាសុត្តន្តប្រីជាឥន្ទ និពន្ធរឿងអំបែងបែក ឆ្នាំ១៨៨៩ រឿងគតិលោក ១៩២០ រឿងកាព្យនិរាសអង្គរ ឆ្នាំ១៩២៦ច្បាប់កូនចៅ បោះពុម្ពឆ្នាំ១៩០០នៅទីក្រុងប៉ារីស។
- តាមាស និពន្ធច្បាប់បណ្តាំតាមាស ឆ្នាំ១៩០៤ បោះពុម្ពឆ្នាំ១៩០៨។
- ព្រះបទុមត្ថេរសោម និពន្ធរឿងទុំទាវ ឆ្នាំ១៩១៥

- លោកយោធានរិន្ទ រ៉ាន់ និពន្ធរឿងសេកសារិកា ១៩២០
- អ្នកស្រីសិទ្ធ និពន្ធរឿងពិម្ពាពិលាប ឆ្នាំ១៩២០
- ឧកញ៉ាវិបុលរាជសេនា នូ កន និពន្ធរឿងពិម្ពានិព្វាន ឆ្នាំ១៩២០ រឿងទាវឯក ឆ្នាំ១៩៤២
- ព្រះភិរម្យភាសា អ៊ូ ហៅង៉ុយ និពន្ធច្បាប់ក្រមង៉ុយ
- យស ងិន និពន្ធរឿងទេវង្សកុមារ(ចៅស្រទបចេក)
- ហ្លួងអគ្គារវិសេស ដួង និពន្ធរឿងល្បើកអក ល្បើកជុចនិងត្រី ល្បើកផ្ការផ្កាំក្លាមខ្យង ល្បើកសារិកា

**២. អ្នកនិពន្ធប្រលោមលោកទំនើប**

អ្នកនិពន្ធប្រលោមលោកទំនើប គឺបណ្តាអ្នកនិពន្ធដែលបានទទួលការសិក្សាពីសាលាទំនើបបារាំង ទទួលឥទ្ធិពលពីការអានសិក្សាប្រលោមលោកបស្ចិមប្រទេស ដែលហូរចូលមកប្រទេសខ្មែរ តាមរយៈអាណាព្យាបាលបារាំង ឬពីសំណាក់ប្រទេសជិតខាងដែលទទួលឥទ្ធិពលលោកខាងលិច ដូចជាអង់គ្លេស។

អក្សរសិល្ប៍ខ្មែរនាសម័យកាលនេះមានលក្ខណៈមនុស្សនិយមដោយអ្នកនិពន្ធលើកយកបញ្ហាមនុស្សមកចោទ ដោះស្រាយទៅតាមតថភាពសង្គម និងខិតខំបង្ហាញពីមធ្យោបាយ ការយល់ឃើញផ្សេងៗរបស់ខ្លួនក្នុងបំណងលុបបំបាត់ភាពអសកម្មក្នុងជីវភាពសង្គម ផ្សះផ្សាទំនាស់សង្គមជាដើម។ ប្រធានបទសំខាន់ៗនាសម័យនោះគឺស្នេហា ដែលស្នេហានេះត្រូវប្រឈមមុខជាមួយបញ្ហាទ្រព្យសម្បត្តិ កិត្តិយស អំណាចផ្តាច់ការរបស់មាតាបិតា អាណាព្យាបាលបារាំងជាដើម។

❖ អ្នកនិពន្ធប្រលោមលោកពាក្យរាយដំបូងក្នុងសម័យនោះ៖

- អ្នកនិពន្ធ ញ៉ុក ថែម និពន្ធរឿងកុលាបប៉ៃលិន ១៩៣៦
- អ្នកនិពន្ធ រីម គីន និពន្ធរឿងសូផាត ១៩៣៨
- អ្នកនិពន្ធ គីម ហាក់ និពន្ធរឿងទឹកទន្លេសាប ១៩៣៩
- អ្នកនិពន្ធ សិទ្ធិ និពន្ធរឿងគូសាងមិត្តមិនទ្រូស្តមិត្ត រឿងចិត្តសត្យា ១៩៤០
- អ្នកនិពន្ធ នូ ហាច និពន្ធរឿងផ្កាស្រពោន ១៩៤០
- អ្នកនិពន្ធ ញ៉ុក ថែម និពន្ធរឿងបិសាចស្នេហា ១៩៤០
- អ្នកនិពន្ធ នង ឈុំ និពន្ធរឿងបៅកើតកុសល ១៩៤១
- អ្នកនិពន្ធ គូច សឹងហាន និពន្ធរឿងកែបមាត់សមុទ្រ ឆ្នាំ១៩៤២
- អ្នកនិពន្ធ ហេង យ៉ាន់ និពន្ធរឿងកំពូលកំសត់ ១៩៤៤
- អ្នកនិពន្ធ ហេង យ៉ាន់ និពន្ធរឿងកំពូលស្នេហា ១៩៤៦
- អ្នកនិពន្ធ អ៊ុម ហ៊ី និពន្ធរឿងមហាអភ័ព ១៩៤៦ រឿងទឹកភ្នែកស្រីស្រុកស្រែ ១៩៤៧
- អ្នកនិពន្ធ នូ កន និពន្ធរឿងកុងឈិន ១៩៤៧

- អ្នកនិពន្ធ ឈុប និពន្ធរឿងព្រាត់ដួងចិត្ត ១៩៤៧
- កញ្ញា ស៊ឹម វណ្ណស៊ី និពន្ធរឿងសង្ឃឹមជានិច្ច ១៩៤៨
- អ្នកនិពន្ធ នូ ហាច និពន្ធរឿងមាលាដួងចិត្ត ១៩៥២
- អ្នកនិពន្ធ រីម គីន និពន្ធរឿងនាងសមាភារី ១៩៥២

**២. សម័យសង្គមរាស្ត្រនិយម (១៩៥៣ដល់១៩៧០)**

សម័យឯករាជ្យ អ្នកនិពន្ធមានសេរីភាពក្នុងការនិពន្ធមាននិន្នាការជាតិនិយម សង្គមនិយមប្រជាធិបតេយ្យ និងប្រជាប្រិយ។ ផលិតកម្មអក្សរសិល្ប៍ប្រកបដោយវឌ្ឍនភាពខ្លាំងក្លា ជាពិសេសនៅរវាងឆ្នាំ ១៩៦៥និង១៩៦៦ គឺប្រទេសទទួលការរីកចម្រើនដ៏ខ្ពង់ខ្ពស់បំផុតក្នុងវិស័យវប្បធម៌ ដោយមានសកលវិទ្យាល័យរីកដុះដាលក្នុងព្រះរាជាណាចក្រកម្ពុជា។

**+ស្នាដៃអក្សរសិល្ប៍មានច្រើនប្រភេទដូចជា៖**

-ប្រលោមលោក

-កំណាព្យ

-រឿងល្ខោន

-សៀវភៅបច្ចេកទេស

-សៀវភៅសិក្សាអប់រំ

-សៀវភៅទាក់ទងនឹងទស្សនវិជ្ជា ជាដើម។

**+អ្នកនិពន្ធនិងស្នាដៃមួយចំនួន នាសម័យសង្គមរាស្ត្រនិយមមានដូចជា៖**

**-លោក អឹម ឆោម** សមាជិកសមាគមអ្នកនិពន្ធខ្មែរ បានទទួលជ័យលាភីអក្សរសិល្ប៍ឥន្ទ្រទេវីនៅឆ្នាំ ១៩៦៥ ចំពោះរឿងនាងរ៉ែនណៃត និងស្នាដៃផ្សេងទៀត គឺរឿងព្រេងខ្មែរជាកំណាព្យ រឿងក្រឡាហោមគង់ជាដើម។

**-លោក ទ្រិញ ង៉ាញ** ជាសមាជិកអ្នកនិពន្ធខ្មែរ តាក់តែងស្នាដៃរឿង ខ្ញុំមានព្រោះអ្វី?

**-លោក ហ៊ែល សុំផា** ជាប្រធានសមាគមអ្នកនិពន្ធខ្មែរ នៅចន្លោះឆ្នាំ១៩៥៧ដល់១៩៧៤ បាននិពន្ធរឿងចោរបិទមុខ រឿងចោរលួចប្រាក់ រឿងចោរភ្នំត្បែង រឿងចិត្តឪពុក និងសិក្សាកថា វចនានុក្រមជាដើម។

**-លោក កេង វ៉ាន់សាក់** ជានិស្សិតមកពីបារាំង លោកបាននិពន្ធរឿងល្ខោន កំណាព្យនិងសិក្សាកថាជាច្រើន រឿងល្ខោនសាច់ពុំបានស៊ីយកឆ្អឹងព្យួរក កំណាព្យចិត្តក្រមុំ គុកកាមកិលេស ជា ដើម។

**៣. អក្សរសិល្ប៍សម័យសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)**

ប្រទេសកម្ពុជានាសម័យនោះ ស្ថិតនៅក្នុងភ្លើងសង្គ្រាមយ៉ាងសន្ធោសន្ធៅ។ អក្សរសិល្ប៍ខ្មែរនៅសម័យនេះចាប់ផ្តើមបែររកទិសដៅថ្មី ហើយមានសន្ទុះរីកចម្រើនខ្លាំងក្លា ព្រមទាំងមានចលនារស់រវើក។

អាជីពជាអ្នកនិពន្ធបានទទួលជីវភាពសមល្មមនឹងរស់នៅស្រួលក្នុងសង្គមតាមរយៈការបោះពុម្ពនិងការលក់ស្នាដៃរបស់ខ្លួន។

**+អត្ថន័យអក្សរសិល្ប៍សម័យនេះមានចរន្តពីរគឺ**

-ទ្រទ្រង់នយោបាយថ្មីបែបសាធារណរដ្ឋ

-រិះគន់របបថ្មីនេះ។

អក្សរសិល្ប៍សម័យនោះ មានប្រភេទប្រលោមលោក កំណាព្យ ល្ខោននិយាយ ឬភាគនិទានរឿងប្រលោមលោក ចម្រៀង និងល្ខោនបាសាក់ ជាដើម។

**+ឈ្មោះអ្នកនិពន្ធនិងស្នាដៃ នាសម័យសាធារណរដ្ឋខ្មែរគឺ**

**-លោក គង្គ ប៊ុនឈឿន** និពន្ធស្នាដៃរឿង ពលទោអភ័ព្វ និងប្រលោមលោកជាច្រើនទៀត។

**-លោក ឡាំង ម៉េងសៀក** និពន្ធស្នាដៃរឿងព្រលឹងម៉ែ ទោសពានរាំង ខ្យល់កំបុតត្បូង ជាដើម។

**-លោក ឃុន ស្រ៊ុន** និពន្ធស្នាដៃ លំនៅចុងក្រោយ ជាកម្រងរឿងនិទាននិងកំណាព្យមួយចំនួន។

**-លោក តាំង វស្សា** និពន្ធរឿងនាងឡៅ-វណ្ណដារ៉ា រឿងអន្ទាក់កាមទេព ជាដើម។

**-លោក ប៊ុណ្ណ ចន្ទម៉ុល** និពន្ធស្នាដៃ ចរិតខ្មែរ គុកនយោបាយ...។

**-លោក គយ សារុន** និពន្ធស្នាដៃ កើតជាមនុស្សនេះ សរសេរជាកំណាព្យ បុប្ផាខ្មៅ។

**-លោក ជិត ខៀវ** និពន្ធស្នាដៃ រឿងខ្មោចព្រាយអសុរកាយ មេម៉ាយប្តី៥ និងស្នាដៃបកប្រែជាភាសាបរទេសមួយចំនួនទៀត។

**-លោក ស៊ូ ចំរើន** និពន្ធស្នាដៃ រឿងជនសង្គ្រាមជ័យ អាម៉ៅឆ្កែខ្ញុំ ពោធិ៍ធិកំបោរ...។

-មានអ្នកនិពន្ធផ្សេងៗទៀតដូចជា សុទ្ធ ប៉ូលីន មិត្ត សាខុន ឌឹកគាម និងទី ជីហួត ជាដើម។

**៤.អក្សរសិល្ប៍សម័យកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)**

ខ្មែរក្រហមបានចាប់ផ្តើមកាន់កាប់អំណាចនាថ្ងៃទី១៧មេសា១៩៧៥ ការធ្វើបដិវត្តផ្តាច់ការដ៏ខ្លាំងក្លាបានធ្វើឱ្យប្រជាជនស្លាប់ជាច្រើនលាននាក់។ កវីនិពន្ធស្លាប់ស្ទើរតែទាំងអស់ អក្សរសិល្ប៍ស្ទើរតែវិនាសមហន្តរាយអស់។

យើងអាចចែកអក្សរសិល្ប៍សម័យកម្ពុជាប្រជាធិបតេយ្យជាដំណាក់កាលៈ

-**ដំណាក់កាលរណសិរ្ស៖** ១៩៧០-១៩៧៥ ស្នាដៃអក្សរសិល្ប៍មានលក្ខណៈបង្រួបបង្រួមកម្លាំងគ្រប់ស្រទាប់វណ្ណៈ គ្រប់សមាភាពបទចម្រៀងនាពេលនោះមាន បទមិត្តដើរព្រៃ អាគិញចង្រៃ...។ រឿងខ្លីៗមានពលីកម្មម៉ែៗ រឿងគំនុំវណ្ណៈ...។

-**ដំណាក់កាលបដិវត្តប្រជាជាតិប្រជាធិបតេយ្យ៖**១៩៧៦-១៩៧៧ អក្សរសិល្ប៍មានភារកិច្ចនិងមានប្រធានបទជុំវិញស្មារតីកសាងនូវប្រទេសជាតិ លុបបំបាត់កាកសំណល់សង្គមចាស់។ ប៉ុល ពត បាននិពន្ធបទ«១៧មេសា មហាជោគជ័យ» ក្រៅពីនេះមានបទ«នៅគ្រប់ការដ្ឋានថ្ងៃណាក៏បុណ្យ»។

**-ដំណាក់កាលបដិវត្តសង្គមនិយម៖**១៩៧៧-១៩៧៨អក្សរសិល្ប៍មានភារកិច្ចរួមចំណែកបម្រើឱ្យមាគ៌ាសង្គមនិយមឆ្អិនឆ្អៅរបស់បក្សកុម្មុយនិស្តកម្ពុជា ជារណសិរ្សសតិអារម្មណ៍ ជាឧបករណ៍នយោបាយក្នុងការអនុវត្តមាគ៌ា«មហាលោតផ្លោះ មហាអស្ចារ្យ»និងប្រឆាំងវាយកម្ទេចរាល់ខ្មាំងរបស់បដិវត្តទាំងក្នុងនិងក្រៅប្រទេស។

គេឃើញមានអ្នកនិពន្ធ ជាប្រជាជនដែលមានការឈឺចាប់ក្នុងរបបនេះបានលួចតាក់តែងបញ្ចេញគំនិតរិះគន់ ដែលជាស្នាដៃមានលក្ខណៈប្រជាជនជាប្រវត្តិសាស្ត្រមានដូចជា៖

-**លោក ជួន ម៉េន** និពន្ធកំណាព្យ«**មើលផែនដីខ្មែរសម័យប៉ុល ពត អៀង សារី**» តាក់តែងនៅឆ្នាំ ១៩៧៦-១៩៧៧

-**លោកស្រី អ៊ុន ស៊ីណន** និពន្ធកំណាព្យ«**សោកនាដកម្មស្រុកមោងឫស្សី**» និពន្ធឆ្នាំ១៩៧៨។

-**លោក កែវ ចិន្តា** និពន្ធកំណាព្យ«ចុកណែនឱរា» នៅឆ្នាំ១៩៧៦»។

## ៥. អក្សរសិល្ប៍សម័យក្រោយថ្ងៃ៧មករា ១៩៧៩ដល់បច្ចុប្បន្ន

**-សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា-រដ្ឋកម្ពុជា៖** នៅខែមករា ១៩៧៩ មានអ្នកនិពន្ធខ្មែរមួយចំនួនបានរស់រានមានភ័ព្វបានរួចផុតពីការស្លាប់នៃរបបខ្មែរក្រហម។ ស្នាដៃមួយចំនួនបានផ្តើមគំនិតក្នុងទិសដៅថ្មីស្របទៅតាមបន្ទាត់នយោបាយថ្មីនៃកម្ពុជា ជាពិសេសគឺសរសេរពីទុក្ខសោកនិងភាពឃោរឃៅនានានៃរបបប្រល័យពូជសាសន៍របស់របបកម្ពុជាប្រជាធិបតេយ្យ។

នៅឆ្នាំ១៩៨៥ លោក **ហ៊ី សុខៃ** បានផ្សាយដំបូងជាល្ខោននិយាយតាមវិទ្យុជាតិនូវរឿង«ក្រញាំមូលធន»ឆ្នាំ១៩៨៧-១៩៨៨យើងក៏ឃើញមានការលេចឡើងនូវប្រលោមលោកខ្លីៗ ដែលប្រធានបទទាក់ទងនឹងមនោសញ្ចេតនាសុទ្ធសាធ បរិយាយនិងឆ្លុះបញ្ចាំងជ្រុងនៃជីវិតក្នុងសង្គមជាបន្តបន្ទាប់ ដូចជារឿង«**យប់កណ្តាលថ្ងៃ**» របស់អ្នកនិពន្ធប៉ុក បុណ្ណសមាជ បានរៀបរាប់ពីជីវិតមនោសញ្ចេតនាពិតៗក្នុងគ្រួសារតូចមួយ ដែលតថភាពសង្គមបានរុញច្រានទៅដល់ភាពជូរចត់នៃជីវភាពគ្រួសារ។

**-សម័យព្រះរាជាណាចក្រកម្ពុជាទី២៖** យើងឃើញថាអក្សរសិល្ប៍ចាប់ផ្តើមរីកចម្រើនបែបសេរីឡើងវិញ។ ប៉ុន្តែវិស័យអក្សរសិល្ប៍ដែលទើបនឹងទទួលសេរីភាពពេញលេញនេះក៏ចាប់ផ្តើមជួបនឹងការប៉ះទង្គិចយ៉ាងខ្លាំងនោះគឺការរីកចម្រើននូវបច្ចេកវិទ្យាវីដេអូ ព្រមទាំងការហូរចូលយ៉ាងខ្លាំង ដោយខ្វះការត្រួតពិនិត្យឱ្យបានត្រឹមត្រូវនៃវប្បធម៌និងខ្សែវីដេអូបរទេសចូលលុកលុយសង្គមកម្ពុជាយើង ហើយសង្កត់វិស័យវប្បធម៌ខ្មែរ វិស័យអក្សរសិល្ប៍ខ្មែរ ដែលទើបតែងើបពីសង្គ្រាមជាងពីរទសវត្សកន្លងមក។

ដូច្នេះអក្សរសិល្ប៍មិនគ្រាន់តែជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងពីការរស់នៅរបស់សង្គមមនុស្សក្នុងសម័យកាលនីមួយៗប៉ុណ្ណោះទេ គឺជាមធ្យោបាយមួយយ៉ាងសំខាន់សម្រាប់ផ្សព្វផ្សាយវប្បធម៌ជាតិថែមទៀត។ ហេតុនេះអ្នកនិពន្ធដែលមានតួនាទីជាអ្នកផ្សាយវប្បធម៌ គប្បីជ្រើសរើសយកគំនិតទស្សនៈយោបល់ល្អៗ

ហើយ សំខាន់ៗទៅតាក់តែងអត្ថបទរបស់ខ្លួនឱ្យបានជាទីគាប់ចិត្តចាប់អារម្មណ៍ហើយជាគុណប្រយោជន៍ដល់អ្នកអានថែមទៀត។

## ស្នេហាក្នុងអក្សរសិល្ប៍

**ស្នេហា**គឺជាប្រធានបទដ៏ជ្រាលជ្រៅនៅក្នុងអក្សរសិល្ប៍ខ្មែរ ដែលចាក់ឫសយ៉ាងជ្រៅនៅក្នុងបរិបទវប្បធម៌ ប្រវត្តិសាស្ត្រ និងសង្គមរបស់កម្ពុជា។ វាជារឿយៗបង្កប់នូវភាពស្មុគស្មាញនៃទំនាក់ទំនងរបស់មនុស្ស តម្លៃសីលធម៌ ការរំពឹងទុកក្នុងសង្គម និងជំនឿខាងវិញ្ញាណ។

នៅក្នុងអក្សរសិល្ប៍ខ្មែរ ស្នេហាមាន៣ប្រភេទទៅតាមចលនាអក្សរសិល្ប៍នីមួយៗគឺ៖

-ស្នេហាតាមបែបព្រាហ្មណ៍និយម

-ស្នេហាតាមបែបពុទ្ធនិយម

-ស្នេហាតាមបែបខេមរនិយម

**១. ស្នេហាតាមបែបព្រាហ្មណ៍និយម៖** ជាស្នេហាដែលកើតឡើងរវាងតួអង្គអាទិទេពនិងវីរនារីដោយទទួលឥទ្ធិពលតាមគោលលទ្ធិព្រាហ្មណ៍និយម ហើយអ្នកឈ្នះទទួលបានស្នេហា តួអង្គឯកស្រី គឺជាកំពូលនារីដែលមានរូបសម្រស់ស្រស់ស្អាតដាច់គេលើលោក និងជាទីចាប់អារម្មណ៍ ព្រមទាំងការចង់បានរបស់ពួកអ្នកខ្លាំង ឬអាទិទេព ដោយការដណ្តើមគ្នា ការប្រយុទ្ធគ្នា និងការប្រឡងប្រជែងជាដើម។

ឧទាហរណ៍៖ រឿងរាមកេរ្តិ៍ ព្រះរាមបាននាងសីតា ជាមហេសីព្រោះព្រះអង្គមានឫទ្ធិចេស្តាខ្លាំងពូកែដែលអាចលើកធ្នូទិព្វរួច។

**២. ស្នេហាតាមបែបពុទ្ធនិយម៖** ជាស្នេហាដែលកើតឡើងពីកម្មផលពីជាតិមុន ហើយជាស្នេហារវាងព្រះពោធិសត្វនិងកន្សែសារ ពេជ្ជ ដែលជាស្នេហាបរិសុទ្ធ ។ ស្នេហានេះជាស្នេហាដោយការសជាតិដោយពុំមានការព្រាត់ប្រាសគ្នាឡើយ។

ឧទាហរណ៍៖ តួអង្គចៅសព្វសិទ្ធិនិងនាងសុវណ្ណកេសរក្នុងរឿងសព្វសិទ្ធិ។ អ្នកទាំងពីរនេះបានគ្នាជាប្តីប្រពន្ធ ព្រោះកាលពីអតីតជាតិមុនលោកចូលភ្លើងទាំងអស់គ្នា ហើយសច្ចាសូមឱ្យបានជួបគ្នាទៅអនាគតជាតិ លុះជាតិក្រោយមកក៏ជួបគ្នាដូចបំណង។

**៣. ស្នេហាតាមបែបខេមរនិយម៖** គឺជាស្នេហារបស់មនុស្សពិតៗជាក់ស្តែងដែលកើតឡើងពីចិត្តអារម្មណ៍របស់តួអង្គឯកប្រុសនិងស្រី ដែលតំណាងឱ្យមនុស្សគ្រប់ប្រភេទក្នុងសង្គមខ្មែរ ហើយវាជាស្នេហាគ្មានព្រំដែន។ ចំពោះស្នេហាគឺមានជួបគ្នា (រឿងកុលាបប៉ៃលិន តួអង្គបានរស់នៅជួបជុំគ្នា) ឬព្រាត់

គ្នា (រឿងទុំទាវ រឿងផ្កាស្រពោន តួអង្គព្រាត់ប្រាសគ្នា) អាស្រ័យទៅលើកត្តាសង្គម និងកត្តាជីវភាពជាដើម។

**+ស្នេហាបែបខេមរនិយមចែកជាបីប្រភេទគឺ**

**-ស្នេហាកាំរន្ទះ** ៖ ជាស្នេហាឃើញភ្លាមស្រឡាញ់ភ្លែត ដោយពុំបានពិចារណា ឬស្គាល់គ្នាជាមុនឡើយ។ ឧទាហរណ៍៖ស្នេហាទុំនិងទាវ។

**-ស្នេហាដោយការផ្សំផ្គុំ**៖ ជាស្នេហាដែលកើតឡើងដោយការផ្សំផ្គុំពីឪពុកម្តាយតាំងពីតូចមក។ ឧទាហរណ៍៖ ស្នេហាប៊ុន ធឿននិងវិធាវី ស្នេហាចៅស្រទបចេកនិងនាងកេសរមាលា...។

**-ស្នេហាដោយការតស៊ូ**៖ ជាស្នេហាដែលកើតឡើងដោយបុរសនិងស្ត្រីតស៊ូស្រឡាញ់គ្នាជម្នះគ្រប់ឧបសគ្គ។ ឧទាហរណ៍៖ ស្នេហារវាងចៅចិត្រនិងយុននារី ស្នេហារវាងសូជាតនិងម៉ានយ៉ាន...។

## ឯកសារយោង

១. ក្រសួងអប់រំ យុវជន និងកីឡា *សៀវភៅគ្រូ ភាសាខ្មែរ ថ្នាក់ទី១០*
២. ក្រសួងអប់រំ យុវជន និងកីឡា *សៀវភៅ អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១១* ,បោះពុម្ពឆ្នាំ២០២១
៣. ក្រសួងអប់រំ យុវជន និងកីឡា *សៀវភៅ អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២* ,បោះពុម្ពឆ្នាំ២០២៣
៤. ក្រសួងអប់រំ យុវជន និងកីឡា *សៀវភៅ ភាសាខ្មែរ ថ្នាក់ទី១០*
៥. នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា អ.យ.ក *វិធីសាស្ត្រនៃការសរសេរតែងសេចក្តី* សម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ទី១១ និងទី១២ ,បោះពុម្ពឆ្នាំ២០១៨
៦. លាង ហាប់អាន *សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ* សម័យនគរភ្នំដល់សម័យឧដុង្គ (សតវត្សទី១ដល់ ១៨៥៩) ,ឆ្នាំ១៩៦៧
៧. គ្រឹង ងា *អរិយធម៌ខ្មែរ* គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ, បោះពុម្ពឆ្នាំ២០០៨
៨. ឈឹម ភារី *ទ្រឹស្តីអក្សរសិល្ប៍* វិទ្យាស្ថានជាតិអប់រំ, កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម ឆ្នាំ ២០១១
៩. ឃីង ហុកឌី *មាលីបទអក្សរសិល្ប៍ខ្មែរសតវត្សទី២០*
១០. គឹម សារឿន ២០១១ *ទស្សនៈអប់រំអក្សរសិល្ប៍ប្រជាប្រិយ*
១១. បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុង *វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរ ក្នុងការលើកកម្ពស់អំណាននៅកម្ពុជា* ២០១៩
១២. ណុន សុខា *រូបារម្មណ៍សិល្បៈក្នុងការតែងនិពន្ធស្នាដៃអក្សរសិល្ប៍*
១៣. នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ២០១២ *ឯកសារបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ភាសាខ្មែរ*